ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

លេខ ១ ត្រីមាសទី១ ឆ្នាំ២០១៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ECOSOCC




កសវ

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

## ក្រុមការងារព្រឹត្តិបត្រ


នាយកគ្រប់គ្រង:
យឹម ណុលសន
និពន្ធនាយក:
អ៊ីវ ថុង
និពន្ធនាយករង:
អ៊ុន វ៉ាល់ឡឺរ៉ូ
ប៊ិច សុខា
ការិយាល័យនិពន្ធ:
នរ៉ាណាឫទ្ធិ អានន្ទដាយ៉ាត
លី គឹមសុខ
ឆយ អូន
ប៊ុន ណារិទ្ធ
កែវ វិចិត្រ
សួង លាងហៃ
ប៉ែន សារឿន
ទូច ចាន់ធី
លឿង ស៊ីម៉ូណា
រ័ត្ន សណ្ដាប់
សរ សុគន្ធីតា
ម៉ម សារិទ្ធ
ស៊ាង សុផល្លា
អ្នកចាត់ចែងផលិត:
អ៊ុន វ៉ាល់ឡឺរ៉ូ
រ័ត្ន សណ្ដាប់
អ្នកចែកផ្សាយ:
អេង រត្នមុនី
សំ សំណាង
សេក វុទ្ធី
ការីកុំព្យូទ័រ:
សយ វាស្នា
យឹម ច័ន្ទតារា


# មាតិកា

ទំព័រ


I- ប្រសាសន៍ ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រធាន ក.ស.វ. ១

II- បទអត្ថាធិប្បាយ " សុភមង្គលនិងការតស៊ូ " ២-៣

III ការពិនិត្យផ្ដល់យោបល់លើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល ៤-៥

២- សេចក្ដីព្រាងច្បាប់ស្ដីពី ការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ៦-៧

៣- គោលនយោបាយជាតិស្ដីពី សុខភាពសិក្សា ៨-៩

IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៨ ១០-១៥

V- កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ១៦-១៩

VI- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ២០-២២

VII- នាទីវប្បធម៌

- ពន្យល់ពាក្យ ២៣
- កម្លាំងសាមគ្គីខ្មែរសម័យអង្គរ ២៤-២៥

VIII- នាទីកំណាព្យ

- ពាក្យកាព្យក្រមង៉ុយប្រដៅសិស្ស ២៦-២៧
- ស្រីខ្មែរ ២៧

IX- នាទីកំសាន្ត

- ធ្វើមិនដូច ២៨
- អញស្អប់បំផុត ២៨


**គំនិតគួរចងចាំ**

" គ្មានសុខដទៃក្រៃលែងជាងសន្តិភាព សេចក្ដីលោភនាំឲ្យអន្តរាយសន្តិភាព "

ព្រះមុនីកោសល **សោម ឈុន**

## I- ប្រសាសន៍ ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រធាន ក.ស.វ.



ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហៅកាត់ថា ក.ស.វ. (ECOSOCC) បានចេញផ្សព្វផ្សាយ**ព្រឹត្តិបត្រប្រចាំខែ**របស់ខ្លួន ចាប់តាំងពីឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០១៨។

ដើម្បីកែលម្អឲ្យបានប្រសើរឡើងនូវទម្រង់និងខ្លឹមសារ គណៈប្រតិបត្តិ ក.ស.វ. បានសម្រេចចេញផ្សាយព្រឹត្តិបត្ររបស់ខ្លួនប្រចាំត្រីមាសវិញ ចាប់ពីឆ្នាំ២០១៩នេះទៅ ជូនអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ ស្វែងយល់លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។

ក.ស.វ. ដែលជាយន្តការនៅអមទីស្តីការគណៈរដ្ឋមន្ត្រី តាមព្រះរាជក្រឹត្យលេខ នស/រកត/០២០៩/១៧៣ ស្តីពីការបង្កើតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានមុខងារនិងភារកិច្ចជារួម៖

- ពិនិត្យតាមដានការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយធ្វើការវិភាគនិងរកមូលហេតុ រួចធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជះឥទ្ធិពលលើការអភិវឌ្ឍប្រទេស និងលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ
- ពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កិច្ចព្រមព្រៀង និងឯកសារផ្សេងៗទៀត ដែលបណ្តាក្រសួងស្ថាប័នដាក់ស្នើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល។
- សហការជិតស្និទ្ធជាមួយក្រសួងស្ថាប័នរដ្ឋ សង្គមស៊ីវិល ផ្នែកឯកជន អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីផ្លាស់ប្តូរបទពិសោធ ទិន្នន័យ និងពត៌មាន

ក.ស.វ. បានបង្កើតក្រុមប្រតិបត្តិលិខិបទដ្ឋានគតិយុត្ត ហៅកាត់ ក.ប.ល. (សម្រាប់អនុវត្តកម្មវិធី RIA) ដែលមានភារកិច្ចបណ្តុះបណ្តាលអំពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ផ្តល់យោបល់ជូនក្រសួងស្ថាប័ន អំពីរបៀបធ្វើរបាយការណ៍វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងធ្វើការផ្សព្វផ្សាយ។

ក.ស.វ. បានបង្កើតក្រុមការងារចំនួនបីទៅតាមក្រសួងស្ថាប័ន ព្រមទាំងក្រុមការងារទទួលបន្ទុករៀបចំចងក្រងឯកសារ ពិនិត្យតាមដានការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមការងារទទួលបន្ទុកកិច្ចការស្រាវជ្រាវ និងក្រុមការងារទទួលបន្ទុករៀបចំព្រឹត្តិបត្រ។

ក.ស.វ. សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះក្រសួងស្ថាប័ន ដែលបានផ្តល់ទិន្នន័យ និងបានចាត់តំណាងចូលរួមប្រជុំជារៀងរាល់ខែ ដែលជាធាតុចូលយ៉ាងសំខាន់គាំទ្រដល់ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ក.ស.វ. ក៏សូមថ្លែងអំណរគុណផងដែរចំពោះ ទ្រង់ សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលតាមដាន ស្រាវជ្រាវ ប្រើប្រាស់ទិន្នន័យ និងអានព្រឹត្តិបត្រព័ត៌មាន ក.ស.វ.។

ក.ស.វ. សង្ឃឹមថា ព្រឹត្តិបត្រព័ត៌មាននេះ នឹងបានជាពន្លឺដល់អ្នកអាន៕

ថ្ងៃសុក្រ ៩រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩

**ប្រធាន**

**យឹម ឆាយលី**

# សុភមង្គលនិងការតស៊ូ

*ដោយបណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង*

បំណងចម្បងរបស់មនុស្សជាតិគឺរស់នៅក្នុងសង្គមមួយក្រោមពន្លឺថ្លានៃសុភមង្គល។ ប៉ុន្តែមនុស្សភាគតិចណាស់ដែលស្វែងរកពន្លឺសុភមង្គលឃើញ ហើយពុំមែនជាសុភមង្គលបណ្ដាច់ទៀតផង គឺគ្រាន់តែជាស្រមោល ឃើញហើយបាត់ទៅវិញក្នុងរយៈពេលដ៏ខ្លី។ ហេតុនេះហើយបានកើតជាបញ្ហាចោទសួររកមធ្យោបាយស្វែងរកសុភមង្គលនេះ។ ជាចម្លើយអ្នកខ្លះអះអាងថា សុភមង្គលពុំអាចសម្រេចបានទេ បើខ្វះការតស៊ូ។ តើការតស៊ូអាចនាំឲ្យស្វែងរកសុភមង្គលឃើញមែនឬ?

សុភមង្គលសម្គាល់នូវសេចក្ដីសុខ ផ្លូវកាយក្ដី ផ្លូវចិត្តក្ដី តាមតែចំណូលចំណង់ចិត្តរបស់មនុស្សម្នាក់ៗ។ ការតស៊ូ គឺការខំប្រឹងប្រែង ព្យាយាមពុះពារឧបសគ្គ ទោះបីហត់នឿយយ៉ាងណាក្ដី លុះត្រាតែបានសម្រេចគោលបំណងជាចុងក្រោយ។ ការតស៊ូនេះ អាចនាំឲ្យមនុស្សទៅរកសុភមង្គលឃើញ តើគេតស៊ូនឹងអ្វី? តស៊ូនឹងអ្នកណា?

តស៊ូនឹងធម្មជាតិ ដើម្បីចំរាញ់យកផលមកចិញ្ចឹមជីវិត ឬច្នៃធម្មជាតិជាឧបករណ៍សម្រាប់បម្រើមនុស្សជាតិ។ កសិករតស៊ូនឹងកំដៅថ្ងៃ នឹងភ្លៀង ខ្យល់ ខំកាប់គាស់ កកាយដីដាំដំណាំ បង្កបង្កើតផលដើម្បីចិញ្ចឹមជីវិតមនុស្សលោក។ កម្មករត្បូងតស៊ូក្រាញនទៀលនឹងអាកាសធាតុត្រជាក់ ពុះពារនឹងជំងឺគ្រុនចាញ់ ជីករណ្ដៅរកត្បូងលក់ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ។ គេអាចរស់នៅដោយសុខសប្បាយរីករាយជាទីបំផុត នៅពេលដែលគេសម្រេចបំណង។

អ្នកប្រាជ្ញខំតស៊ូរុករក ពិសោធ ពិនិត្យភាវៈ ធម្មជាតិ ដើម្បីបង្កើតឧបករណ៍គ្រប់បែបយ៉ាង ដែលជាមធ្យោបាយធ្វើឲ្យមនុស្សបានសុខស្រួល។ សព្វថ្ងៃនេះគេអាចធ្វើដំណើរកាត់ពីទ្វីបមួយទៅទ្វីបមួយ តាមជើងទឹកក៏បាន តាមជើងអាកាសក៏បាន តាមរថភ្លើងក៏បាន។ ថ្នាំពេទ្យក៏សំបូរហូរហៀរ សម្រាប់ព្យាបាលរោគរបស់មនុស្សជាតិ។ ទាំងអស់នេះពុំមែនកើតឡើងដោយឯកឯងនោះទេ គឺសុទ្ធតែកើតឡើងដោយការតស៊ូយ៉ាងស្វិតស្វាញបំផុត។

រួមមក ការតស៊ូរបស់មនុស្សក្នុងការប្រយុទ្ធនឹងធម្មជាតិ ពុំមែនគ្រាន់តែនាំមកនូវសុភមង្គលសម្រាប់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែនាំមកនូវសុភមង្គលសម្រាប់សង្គមជាតិថែមទៀត។ ប្រសិនបើម្នាក់ៗតស៊ូរៀងៗខ្លួនតាមមុខរបរ តាមតួនាទី តាមចំណូលចិត្ត នោះភោគផលនឹងកើតព្រោងព្រាត ហើយអាចប្ដូរគ្នាប្រើប្រាស់តាមសេចក្ដីត្រូវការ។ បានសេចក្ដីថា បើមនុស្សទាំងអស់គ្នាតស៊ូនឹងការងារ សង្គមនោះអាចរកសុភមង្គលឃើញ។ ផ្ទុយទៅវិញ បើមានមនុស្សខ្លះមិនតស៊ូនឹងធម្មជាតិ មិនជួយបង្កើតផល គឺគ្រាន់តែចាំទទួលផលមកប្រើប្រាស់បំពេញបំណងខ្លួន តាមមធ្យោបាយឬកលល្បិចអាក្រក់ណាមួយនោះ អយុត្តិធម៌នឹងមានកំណកំណើតជាប្រាកដ ព្រោះជួនកាលអ្នកខំតស៊ូនោះ ត្រូវគេប្រវ័ញ្ចយកផលអស់ទៅវិញ ហើយអ្នកនៅស្ងៀមឡើងជាម្ចាស់ភោគផលយ៉ាងខ្ពស់ត្រដែត។ ក្នុងស្ថានភាពបែបនេះ តើគេត្រូវដោះស្រាយបែបណា?

ត្រូវប្រយុទ្ធតស៊ូនឹងមនុស្សគ្នាឯងទៀត។ តស៊ូនឹងមនុស្សណាដែលមានគំនិតអាក្រក់ គិតតែឆ្អួលទ្រព្យធ្វើស្រែលើខ្នងរាស្ត្រខ្សត់ខ្សោយ ពោលគឺត្រូវតស៊ូនឹងពពួកមនុស្សអត្តទត្ថភាពដែលជាប្រភេទមនុស្សអសកម្មធ្វើឲ្យរាំងស្ទះដល់ការរីកចម្រើនរបស់សង្គម ហើយសុភមង្គលនឹងត្រូវបាត់បង់រលត់ជាមួយគ្នា។ ជាក់ស្ដែង

ដើម្បីផ្ដល់ជូនសុភមង្គលដល់ប្រជារាស្ត្រខ្មែរ សម្តេចតេជោ **ហ៊ុន សែន** បានបូជាអស់កម្លាំងកាយ កម្លាំងចិត្ត ជម្នះរាល់ឧបសគ្គផងទាំងពួង អភិវឌ្ឍកម្ពុជាបច្ចុប្បន្នបានរុងរឿងត្រដែតត្រដឹមដូចអារ្យប្រទេសនានា។ សម្តេចបានលើកឡើងនូវអនុសាសន៍ចំពោះមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ នូវអភិក្រមទាំងប្រាំគឺ ឆ្លុះកញ្ចក់ ងូតទឹក ដុះក្អែល ព្យាបាល វះកាត់ ក្នុងចេតនាតស៊ូកសាងមនុស្សសុចរិត បម្រើសង្គមជាតិឲ្យមានវឌ្ឍភាពកាន់តែខ្លាំងក្លាឡើង។ ប្រជាជនកម្ពុជាបានចារឹកទុកនូវមហាពលិកម្មរំដោះជាតិពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ជាវីរសកម្មគ្មានពីរក្នុងប្រវត្តិសាស្ត្រកម្ពុជា។ សម្តេចតេជោ **ហ៊ុន សែន** ជាយុទ្ធិកសន្តិភាពគំរូ ជាវីរជនស្នេហាជាតិពិតៗនាយុគសម័យយើងនេះ។

ការតស៊ូប្រយុទ្ធនឹងធម្មជាតិបានរំដោះមនុស្សឲ្យផុតពីការគំរាមកំហែងនៃធម្មជាតិ បាត់ខ្លាចការគោរពលើធម្មជាតិអាទិទេពទៀត ហើយធ្វើឲ្យមនុស្សក្លាយជាម្ចាស់ធម្មជាតិវិញ។ ការតស៊ូនឹងមនុស្សគ្នាឯង បានរៀបចំសង្គមឲ្យមានយុត្តិធម៌។ ការតស៊ូបែបនេះនាំឲ្យគេស្វែងរកសុភមង្គលឃើញ។ តែការតស៊ូមានច្រើនបែបទៀត តើការតស៊ូសុទ្ធតែនាំឲ្យសម្រេចសុភមង្គលទាំងអស់ឬអ្វី?

ការតស៊ូខ្លះនាំឲ្យវិនាសទៅវិញ។ ការតស៊ូខាងបំផ្លាញជាតិ តស៊ូក្បត់ជាតិឯង បម្រើបរទេស តស៊ូខាងបង្កើនអំណាចផ្តាច់ការ តស៊ូខាងប្រឆាំងមតិ ឬផលប្រយោជន៍មហាជន គឺសុទ្ធតែបំផ្លិចបំផ្លាញ មិននាំឲ្យសម្រេចសុភមង្គលឡើយ។ យ៉ាងណាមិញ ការតស៊ូរបស់បាឡាត់ស្រុកសង្កែ ថៅកែជាន់ ត្រូវថៅចិត្រ និងក្រុមកម្មករជីកត្បូង លុបឈ្មោះចេញពីពិភពលោកនេះ ព្រោះតែអំពើចោរកម្មបម្រើសេចក្តីលោភលន់របស់ខ្លួន។ អរជូន ម្តាយទាវ ក្នុងរឿងទុំទាវ ដែលខំតស៊ូយ៉ាងស្វិតស្វាញបំផុត ខាងកាប់សម្លាប់រាស្ត្រ ស្លូតត្រង់ឥតជំនុំ ត្រូវវិនាសអន្តរធាន។ សុគ្រីពបានតស៊ូប្រឆាំងនឹងពាលី យកកម្លាំងបរទេសមកប្រើត្រូវធ្លាក់ខ្លួនជាខ្ញុំបម្រើព្រះរាមជាច់ថ្លៃ។ បានសេចក្តីថា ការតស៊ូបែបនេះ ពុំអាចរកសុភមង្គលឃើញឡើយ។

ម៉្យាងទៀត ការតស៊ូប្រឆាំងនឹងពួកអ្នកកាន់អំណាចផ្តាច់ការនិយម ពុំមែនចេះតែសម្រេចបានតាមបំណងនោះទេ គ្រោះថ្នាក់តែងតែកើតមានឡើងជាធម្មតា។ យ៉ាងណាមិញ ទុំទាវ ដែលបានតស៊ូយ៉ាងស្វិតស្វាញបំផុតប្រឆាំងនឹង អរជូន ម្តាយទាវ ត្រូវទទួលគ្រោះថ្នាក់ដល់ស្លាប់ទៅវិញ។

ដូចនេះ យើងឃើញថា ការតស៊ូអាចនាំមកនូវផលល្អនិងផលអាក្រក់តាមសមត្ថភាព វិធី និងបំណងរបស់មនុស្ស។ បើយ៉ាងនេះ ការតស៊ូបែបណាដែលជាមធ្យោបាយរកសុភមង្គលពិត?

ការតស៊ូប្រឆាំងកំទេចពួកអ្នកបង្កអំពើអយុត្តិធម៌ ពួកជនទុច្ចរិត ដើម្បីប្រយោជន៍សាធារណៈ ប្រយោជន៍ជាតិឬមនុស្សជាតិ ការតស៊ូក្នុងការបង្កើតផលចេញពីធម្មជាតិ គឺជាមធ្យោបាយអាចធ្វើឲ្យសម្រេចសុភមង្គលបាន។ ពិតមែនហើយការតស៊ូបែបនេះតែងតែមានគ្រោះថ្នាក់ ជួនកាលដល់បាត់បង់ជីវិត ប៉ុន្តែពុំមានន័យថាពុំបានសម្រេចសុភមង្គលនោះទេ ព្រោះការតស៊ូប្រយុទ្ធនឹងពួកអគតិមួយក្រុមដែលពឹងផ្អែកបរទេសទាំងស្រុង ពូកែខាងបោកប្រាស ភូតកុហក កាឡៃសភាពការណ៍សទៅជាខ្មៅ ត្រូវការការបង្កើនស្មារតីប្រុងប្រយ័ត្នគ្រប់ពេលវេលា កុំឲ្យពួកនេះបំភ័ន្តផ្លាស់ប្តូរសភាពការណ៍បាន នោះយើងអាចដណ្តើមជ័យជំនះបានជាដរាប ហើយសុភមង្គលក៏លេចចេញកើតជារូបរាងឡើងជាប្រាកដ។

អាស្រ័យហេតុនេះ ដើម្បីសុភមង្គលរបស់មនុស្សជាតិ យើងត្រូវតែខំប្រឹងប្រែងតស៊ូ តស៊ូនឹងធម្មជាតិដើម្បីទាញយកប្រយោជន៍មកបម្រើមនុស្ស តស៊ូនឹងមនុស្សគ្នាឯងដើម្បីរៀបចំសង្គមឲ្យមានលក្ខណៈល្អទំនើបមានយុត្តិធម៌ គោរពតម្លៃមនុស្ស មានសិទ្ធិសេរីភាព ពោលគឺសង្គមមួយប្រកដោយលទ្ធិប្រជាធិបតេយ្យ ផ្តល់នូវសុភមង្គលដល់ប្រជារាស្ត្រ តាមរយៈការខំកាត់បន្ថយភាពក្រីក្រជាអតិបរមា៕

## ១- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

### ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល

កាលពីថ្ងៃព្រហស្បតិ៍ ទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង៨:៣០នាទីព្រឹក នៅទីស្តីការក្រសួងមុខងារសាធារណៈ តាមការស្នើសុំរបស់ក្រសួង និងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយក-រដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកចំនួន ២រូប នៃក្រុមប្រឹក្សាសេដ្ឋ-កិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានចាត់តាំងឲ្យចូលរួម ក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងព្រះ-រាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល។

ការប្រជុំពិភាក្សាបានផ្តោតជាដំបូងទៅលើទិដ្ឋភាពរួមនៃសេចក្តីព្រាង ហើយជាបន្ទាប់ទើបចូលទៅខ្លឹមសារនៃអត្ថបទមួយជំពូកម្តងៗ។

សេចក្តីព្រាងព្រះរាជក្រឹត្យនេះ មានគោលបំណងរៀបចំសាលាភូមិន្ទរដ្ឋបាល ហៅកាត់ថា "ស.ភ.រ." ជាគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈចំណុះក្រសួងមុខងារសាធារណៈ ដើម្បីលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលដំបូង ការបណ្តុះបណ្តាលបន្ត និងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងវិស័យសាធារណៈ។

លើទិដ្ឋភាពរួមនេះ តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សង្កេតឃើញថាការរៀបចំនេះ ស្រដៀងទៅនឹងការប្រែក្លាយសាលាទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវនឹងពាក្យបារាំងថា Etablissement public à caractère administratif (EPA) ដែលជានីតិបុគ្គលសាធារណៈទទួលបន្ទុកចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈជាអាទិ៍ សេវាមានលក្ខណៈរដ្ឋបាល សង្គមកិច្ចសុខាភិបាល វប្បធម៌ អប់រំវិទ្យាសាស្ត្រ និងបច្ចេកទេស ដែលខុសគ្នាពីគ្រឹះស្ថានសាធារណៈមួយប្រភេទទៀត ដែលមានលក្ខណៈសេដ្ឋកិច្ច(ឧស្សា-ហកម្ម និងពាណិជ្ជកម្ម) ត្រូវនឹងពាក្យបារាំងថា Etablissement public à caractère industriel et commercial (EPIC) ផលិតផលទំនិញ ឬធ្វើសេវាសម្រាប់ទីផ្សារ។ គ្រឹះស្ថានសាធារណៈទាំងពីរប្រភេទ រដ្ឋបាល និងសេដ្ឋកិច្ចមានកម្មវត្ថុបម្រើសេវាសាធារណៈ មានស្វ័យភាពហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន ជាអាណាព្យាបាលបច្ចេកទេស ហើយស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។ បើក្នុងន័យនេះ ការរៀបចំ និងការប្រព្រឹត្តិទៅនៃសាលាភូមិន្ទរដ្ឋបាលនេះ ត្រូវរៀបចំដោយអនុក្រឹត្យ ដូចការចង្អុលបង្ហាញរបស់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្មី ដែលជំនួសព្រះរាជក្រឹត្យចាស់ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិ-យុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ប៉ុន្តែសាលាភូមិន្ទរដ្ឋបាល មានព្រះរាជក្រឹត្យបង្កើតតាំងពីឆ្នាំ១៩៩៥ ដែលត្រូវបានកែសម្រួលនៅឆ្នាំ២០១៤ គឺមុនព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងចាស់ទាំងថ្មី។

ក្នុងការពិចារណាបែបបនេះ យោងទៅលើ

ទិដ្ឋភាពច្បាប់ ទៅលើការអនុវត្តកន្លងមក និងទៅលើការរីកចម្រើននាពេលបច្ចុប្បន្នរបស់សាលា ក៏ដូចជាការអនុវត្តល្អរបស់សាលា ដែលមានបេសកកម្មបណ្តុះបណ្តាលប្រហាក់ប្រហែលគ្នានៅសឹង្ហបុរី និងនៅបារាំង (ENA) ជាដើម តំណាង ECOSOCC ដែលបានចូលរួម បានឯកភាពជាមួយអង្គប្រជុំទាំងមូលលើការរៀបចំសាលា ជាគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ចំណុះក្រសួងមុខងារសាធារណៈ មានលក្ខណៈថ្មី មានស្វ័យភាពរដ្ឋបាលនិងហិរញ្ញវត្ថុ ប៉ុន្តែមិនមែនជាគ្រឹះស្ថានរកស៊ីយកផលចំណេញអ្វីឡើយ ពីព្រោះការបណ្តុះបណ្តាលធ្វើឡើងតែក្នុងរង្វង់មន្ត្រីរាជការសាធារណៈប៉ុណ្ណោះ។

ក្នុងន័យនេះ អង្គប្រជុំបានឯកភាពដាក់ចំណងជើងសេចក្តីព្រាងព្រះរាជក្រឹត្យថា " ព្រះរាជក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល " ឲ្យពេញសេចក្តីដើម្បីជំនួសពាក្យ "រៀបចំ" ឬពាក្យ "បង្កើត" ដែលមាននៅក្នុងសេចក្តីព្រាង និងដើម្បីឲ្យស្របតាមការសម្រេចឲ្យអនុវត្តកន្លងមកផង។ ធ្វើបែបនេះ គឺយើងនៅរក្សាទម្រង់នៃសេចក្តីព្រាងដដែលគឺជាព្រះរាជក្រឹត្យ ហើយខ្លឹមសារនៃព្រះរាជក្រឹត្យមុន ក៏មិនមានអ្វីផ្ទុយគឺដូចជាការកែសម្រួលបន្ថែមខ្លឹមសារឲ្យបានទូលំទូលាយទៅតាមការវិវត្តជាក់ស្តែងនៃសង្គមជាតិ ក៏ដូចជាការវិវត្តនៃទំនាក់ទំនងអន្តរជាតិ ដោយមិនយោងទៅរកព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលនោះឡើយ ពីព្រោះមិនមែនជាគ្រឹះស្ថានសាធារណៈ ដូចមន្ទីរពេទ្យកាល់ម៉ែត ឬវិទ្យាស្ថានស្រាវជ្រាវសុខភាពសាធារណៈក្រោមអាណាព្យាបាលរបស់ក្រសួងសុខាភិបាលនោះឡើយ ប៉ុន្តែគឺជាគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ ចំណុះក្រសួងមុខងារសាធារណៈ មានថវិកាស្វយ័តសម្រាប់គាំទ្រដំណើរការរបស់ខ្លួន ដែលជាកញ្ចប់ថវិកាផ្ទាល់ដោយឡែក ក្នុងថវិការបស់ក្រសួងមុខងាសាធារណៈ។

ជារួម ការរៀបចំបែបនេះ គឺជាលក្ខណៈមួយដោយឡែកនៃការរៀបចំអង្គភាពរដ្ឋដែលស្ថិតនៅចំណុះក្រសួង ហើយមានថវិកាស្វយ័តសម្រាប់គាំទ្រដំណើរការរបស់ខ្លួនក្នុងកញ្ចប់ថវិកាផ្ទាល់របស់ក្រសួង។

បន្ទាប់ពីបានឯកភាពគ្នាលើទិដ្ឋភាពរួម លើការរៀបចំជាថ្មីនូវចំណងជើងនៃសេចក្តីព្រាងព្រះរាជក្រឹត្យ អង្គប្រជុំបានបន្តការពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាង ដោយពិនិត្យមួយជំពូកម្តងៗ។

អង្គប្រជុំបានឯកភាពគ្នាលុបចោលមាត្រាខ្លះ ដែលមិនមានអនុភាពគតិយុត្ត បញ្ចូលមាត្រាខ្លះដែលមានន័យប្រហាក់ប្រហែលគ្នាជាមួយគ្នា បំបែកមាត្រាខ្លះដែលវែង ដើម្បីឲ្យមានសង្គតិភាពក្នុងការតាក់តែងសេចក្តី និងកែមាត្រាខ្លះ ដើម្បីឲ្យស្របទៅតាមការកែសម្រួលថ្មី ដែលអង្គប្រជុំបានឯកភាព ព្រមទាំងមានការបញ្ចូលបន្ថែមនូវជំពូកអន្តរប្បញ្ញត្តិមួយទៀត ដើម្បីរក្សាសុពលភាពនៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនដែលកំពុងអនុវត្តនៅពេលព្រះរាជក្រឹត្យចូលជាធរមាន ហើយលិខិតបទដ្ឋានថ្មីពុំទាន់បានរៀបចំមកជំនួស។

កិច្ចប្រជុំពិភាក្សាដែលចាប់ផ្តើមពីម៉ោង ៨:៣០នាទីព្រឹក ត្រូវបានបញ្ចប់នៅវេលាម៉ោង ១១:៣០នាទីព្រឹកនាថ្ងៃដដែល ដោយសន្យាថា នឹងទុកឲ្យក្រុមការងាររៀបចំសេចក្តីព្រាងរបស់ក្រសួង យកសេចក្តីព្រាងទៅកែសម្រួលទៅតាមស្មារតីនៃអង្គប្រជុំ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងបន្តនីតិវិធីដាក់សេចក្តីព្រាង ទៅប្រមុខរាជរដ្ឋាភិបាល យកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា។

សូមបញ្ជាក់ជូនថា ព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសាលាភូមិន្ទរដ្ឋបាល បានចូលជាធរមានហើយ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩៕

# ២- សេចក្តីព្រាងច្បាប់ស្តីពី

## ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

អនុលោមតាមមាត្រា៥៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ឆ្នាំ២០១៤-២០១៨ បានតម្រូវឲ្យរាជរដ្ឋាភិបាលរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋឲ្យទាន់ពេលកំណត់ និងមានប្រសិទ្ធភាពខ្ពស់។ សេចក្តីព្រាងនេះនឹងក្លាយជាច្បាប់គោល ក្នុងការកំណត់យន្តការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាសារវន្ត ដែលស៊ីចង្វាក់ជាមួយច្បាប់កំពូល និងលិខិតបទដ្ឋានគតិយុត្តដែលមានចរិតគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដទៃ មានជាអាទិ៍ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ស្តីពីសម្បទានឆ្នាំ២០០៧ ច្បាប់ស្តីពីរ៉ែឆ្នាំ២០០១ ច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ នៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈឆ្នាំ២០០៦ បទបញ្ជារាជរដ្ឋាភិបាលលេខ៣០ បប. ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឆ្នាំ១៩៩៧ សារាចរណែនាំលេខ០៧ សរ. ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៤ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

សេចក្តីព្រាងច្បាប់នេះ មានគោលបំណងគ្រប់គ្រង និងអភិវឌ្ឍទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព សង្គតិភាព នីត្យានុកូលភាព បូរណភាព និងចីរភាព សំដៅចូលរួមចំណែកបម្រើឧត្តមប្រយោជន៍នៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីព្រាងច្បាប់នេះមានគោលដៅកំណត់ក្របខណ្ឌច្បាប់ និងស្ថាប័ន ជាគោលសម្រាប់ធានាការគ្រប់គ្រងនិងអភិវឌ្ឍទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទ អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានស្នើសុំកិច្ចសម្របសម្រួលពីទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបន្តនីតិវិធីនៃការពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ក្នុងក្របខណ្ឌកិច្ចប្រជុំអន្តរក្រសួងស្ថាប័នកម្រិតនយោបាយ តាមរយៈលិខិតលេខ២០០៦០ សហវ.អទច ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨។

បន្ទាប់ពីទទួលបានសំណើខាងលើនេះ ទីស្តីការគណៈរដ្ឋមន្ត្រីបានរៀបចំកិច្ចប្រជុំជំនាញបច្ចេកទេសចំនួន៤លើក ដើម្បីពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់នេះឲ្យកាន់តែល្អប្រសើរឡើង។

កិច្ចប្រជុំជំនាញបច្ចេកទេសលើកទី១ ធ្វើឡើងកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដឹកនាំដោយសហប្រធាន លោកជំទាវ **តាល់ ណែអ៊ីម** អនុប្រធាន ECOSOCC និងឯកឧត្តម **អ៊ុំ ម៉ិន ធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ដោយមានឯកឧត្តម **ខី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាតំណាងក្រសួងសាមី។





កិច្ចប្រជុំជំនាញបច្ចេកទេសលើកទី២ ធ្វើឡើងកាលពីថ្ងៃទី១៤-១៥ ខែកុម្ភៈ លើកទី៣ កាលពីថ្ងៃទី២០ ខែកុម្ភៈ និងលើកទី៤ កាលពីថ្ងៃទី២៥-២៦ ខែកុម្ភៈ ឆ្នាំ២០១៩ ដឹកនាំដោយសហប្រធាន ឯកឧត្តម **អ៊ុច ថោងសេង** សមាជិក ECOSOCC និងឯកឧត្តម **លី ច័ន្ទ តុលា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដោយមាន ឯកឧត្តម



**ទី តាឃី** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាតំណាងក្រសួងសាមី។ ជាលទ្ធផល អង្គប្រជុំបានពិភាក្សាបញ្ចប់ និងបានឆ្លងសេចក្ដីព្រាងច្បាប់នេះក្នុងកិច្ចប្រជុំជំនាញបច្ចេកទេសនៃទីស្ដីការគណៈរដ្ឋមន្ត្រីជាស្ថាពរ៕



## ៣- គោលនយោបាយជាតិស្ដីពី

## សុខភាពសិក្សា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញចក្ខុវិស័យក្នុងការប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ មុំទី១ អំពីការអភិវឌ្ឍធនធានមនុស្ស និងមុំទី៣ អំពីការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ ក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព ផលិតភាព ការងារខ្ពស់ និងសុខភាពរឹងមាំ។

ក្នុងវិស័យនេះ រាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សុខភាពសិស្សា ដោយបានរៀបចំជាសំណុំយុទ្ធសាស្ត្រ និងសកម្មភាពអន្តរកម្ម រវាងគ្រឹះស្ថានសិក្សា និងសេវាកម្មសុខភាពនានា ដើម្បីលើកកម្ពស់សុខភាព តាមរយៈការអប់រំសុខភាព ការបង្ការជំងឺ ការផ្ដល់សេវាកម្មសុខភាពចាំបាច់ ការលើកកម្ពស់អនាម័យ បរិស្ថាន និងការផ្គត់ផ្គង់ទឹកស្អាតដល់បុគ្គលិកអប់រំនិងអ្នកសិក្សាជាដំណាក់កាលៗ។

គោលនយោបាយជាតិស្ដីពីសុខភាពសិក្សានឹងចូលរួមលើកកម្ពស់គុណភាពអប់រំដើម្បីកម្ពុជាសម្រេចបានគោលដៅនៃការអប់រំតាមរយៈការផ្ដល់នូវចំណេះដឹងសុខភាព ស្របតាមការលូតលាស់រាងកាយនិងស្មារតី ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ បំណិនសម្រាប់បង្ការជំងឺឆ្លង ជំងឺមិនឆ្លង គ្រោះថ្នាក់ផ្សេងៗ និងវិធីជួយសង្គ្រោះបឋម គុណតម្លៃ និងឥរិយាបថ ដែលនាំឲ្យពួកគេអភិវឌ្ឍខ្លួនប្រកបដោយសុខភាពពេញលេញ ទាំងកាយ ប្រាជ្ញាស្មារតី និងចេះទទួលខុសត្រូវខ្ពស់រាល់ទង្វើរបស់ខ្លួន។

អនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្ដីពីការអប់រំ ដើម្បីឆ្លើយតបតាមភាពរីកចម្រើន និងតម្រូវការខាងលើ ព្រមទាំងជំរុញការអនុវត្តសិទ្ធិមនុស្ស រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំគោលនយោបាយជាតិ ស្ដីពីសុខភាពសិក្សា ដែលតម្រូវឲ្យមានការចូលរួមជាពហុវិស័យពាក់ព័ន្ធ ប្រកបដោយសង្គតិភាព និងអាចអនុវត្តបានក្នុងការចូលរួមអភិវឌ្ឍមូលធនមនុស្សដែលជាបំណងប្រាថ្នាដ៏ទទូចរបស់ប្រជាជនកម្ពុជា ដើម្បីកសាងកម្ពុជាក្លាយជាអរិយប្រទេសនាពេលអនាគត។

ដើម្បីអនុវត្តគោលនយោបាយជាតិស្ដីពីសុខភាពសិក្សាឲ្យបានជោគជ័យត្រូវមានយុទ្ធសាស្ត្រ ៨ចំណុច ដូចបានកំណត់ដូចខាងក្រោម៖

១. អភិវឌ្ឍក្របខណ្ឌច្បាប់និងមុខងារ

២. លើកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា និងបុគ្គលិកអប់រំ

៣. លើកកំម្ពស់ការផ្ដល់អាហារូបត្ថម្ភ

៤. លើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

៥. លើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាពបរិយាបន្នជាសុកភាព និងមេត្រីភាព

៦. លើកកម្ពស់ការអប់រំសុខភាព

៧. លើកកម្ពស់ការអនុវត្តបំណិនសុខភាព

៨. លើកកម្ពស់ការចូលរួមពីភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសុខភាពសិក្សា។

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់តាមផែនការសកម្មភាព ៥ចំណុច ដូចខាងក្រោម៖

- ការបង្កើតយន្តការ
- ការបង្កើតក្របខណ្ឌតិតយុត្ត
- ការគាំទ្រហិរញ្ញវត្ថុ
- ការបណ្ដុះបណ្ដាលធនធានមនុស្ស
- ដំណើរការអនុវត្តគម្រោង។

ដើម្បីឲ្យគោលនយោបាយជាតិនេះ មានវិសាលភាព និងអនុវត្តស្របតាមបរិបទកម្ពុជា ចាំបាច់ត្រូវមានប្រព័ន្ធតាមដានត្រួតពិនិត្យវាយតម្លៃ ពិនិត្យឡើងវិញ និងសំណើកែលម្អការអនុវត្ត។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំ និងជឿជាក់លើការប្ដេជ្ញាចិត្ត ស្មារតីទទួលខុសត្រូវខ្ពស់ និងកិច្ចសហប្រតិបត្តិការគ្នាដ៏ល្អរបស់ក្រសួង ស្មារតីអនុវត្តនៃរាជរដ្ឋាភិបាលកម្ពុជា និងជំរុញការលើកកម្ពស់សុខភាពដល់បុគ្គលិកអប់រំ និងអ្នកសិក្សានៅតាមគ្រឹះស្ថានសិក្សា ប្រកបដោយគុណភាព ប្រសិទ្ធភាព ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំ និងការកសាងគុណភាពមនុស្ស ប្រកបដោយសក្ដានុពល ក្នុងការចូលរួមចំណែកអភិវឌ្ឍសង្គមជាតិ។

សេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីសុខភាពសិក្សា ត្រូវបានដាក់ប្រជុំពិភាក្សាក្នុងកិច្ចប្រជុំជំនាញបច្ចេកទេសកាលពីថ្ងៃទី៣១ខែមករា ឆ្នាំ២០១៩ ក្រោមការដឹកនាំដោយសហប្រធាន លោកជំទាវ **ខួត ធនផ្កា** សមាជិក គ.ស.វ. និង ឯកឧត្ដម **លី ច័ន្ទតុលា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និង ឯកឧត្ដម **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ តំណាងសាមីក្រសួងអប់រំ យុវជន និងកីឡា។

សេចក្ដីព្រាងនេះ ត្រូវបានឆ្លងកិច្ចប្រជុំអន្តរក្រសួង ពិនិត្យនិងផ្ដល់យោបល់រួចរាល់ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្ដម **អ៊ីន វីរៈជាតិ** រដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី ឯកឧត្ដម **ម៉ែន សារឿន** និង ឯកឧត្ដម **ម៉ៅ ប៊ុនលិន** សមាជិក គ.ស.វ. និង ឯកឧត្ដម **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា៕

**គំនិតគួរចងចាំ**

" នំផ្អែមជាសត្រូវអ្នកប្រមឹក ការរវើកជាសត្រូវអ្នកស្ងប់ស្ងាត់
ព្រានប្រមាញ់ជាសត្រូវដល់ពួកសត្វ មិនប្រតិបត្តិជាសត្រូវដល់ក្បួនច្បាប់ "

សម្ដេចព្រះមហាសុមេធាធិបតីសង្ឃរាជា
**ជួន ណាត ជោតញាណោ**

# IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៨



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីអនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

អតិផរណាឆ្នាំ២០១៨ មានអត្រាស្មើនឹង២,៥% ក្នុងនោះក្រុមទំនិញដែលឡើងថ្លៃខ្ពស់ជាងអត្រាមធ្យមនេះ គឺភោជនីយដ្ឋាន (៥,៩%) ការដឹកជញ្ជូន (២,៩%) និងទំនិញនិងសេវាកម្មផ្សេងៗ (២,៨%)។ ក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃថយចុះមាន ការសិក្សា (-0,១%) ការកម្សាន្តនិងវប្បធម៌ (-0,៣%) និងទូរគមនាគមន៍ (-0,៧%)។ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មាន ឧស្ម័ន ៧% ប្រេងសាំង ៦% ប្រេងម៉ាស៊ូត ៦% និងត្រីស្រស់ ៤%។ តារាងខាងក្រោមបង្ហាញអតិផរណាប្រចាំខែ ក្នុងអំឡុង ២០១៦-២០១៨ (ជាកំណើនធៀបនឹងខែដូចគ្នាឆ្នាំមុន)។

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ២,0% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |
| ២០១៧ | ៤,៤% | ៤,0% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| ២០១៦ | ៣,0% | ២,៣% | ២,0% | ២,៨% | ៣,២% | ៣,៣% | ៣,0% | ២,៩% | ៣,0% | ៣,៣% | ៣,៦% | ៣,៩% | ៣,0% |

➢**អត្រាប្តូរប្រាក់:**

ប្រាក់រៀលមានស្ថេរភាពធៀបនឹងប្រាក់បាត ប៉ុន្តែមានការឡើងថ្លៃ0,៥%ធៀបនឹងប្រាក់ដុល្លារអាមេរិក និងឡើងថ្លៃ២,២%ធៀបនឹងប្រាក់ដុង។ នាចុងឆ្នាំ២០១៨ អត្រាប្តូរប្រាក់រៀល មានស្ថានភាពដូចខាងក្រោម:

- ប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានអត្រា៤០១៨រ/ដុល្លារ
- ប្រាក់រៀលធៀបនឹងដុងវៀតណាមមានអត្រា0,១៧៤រ/ដុង
- ប្រាក់រៀលធៀបនឹងបាតថៃមានអត្រា១២៤រ/បាត។

## ២) ស្ថានភាពថវិកាជាតិ

យោងតាមស្ថិតិដែលឆ្លងកាត់ធនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១៨នេះ អនុវត្តបានចំនួន ១៩.៩៥៥,៦ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤.៩៨៨,៩លានដុល្លារ) ស្មើនឹង ១១២% នៃផែនការ ក្នុងនោះ ចំណូលចរន្ត ១៩.៥៤៩,១ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤.៨៨៧,៣លានដុល្លារ) ស្មើនឹង ១១២% នៃផែនការ និងចំណូលមូលធន៤០៦,៥ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១០១,៦លានដុល្លារ)។

បើធៀបនឹងឆ្នាំ២០១៧ ចំណូលថវិកាជាតិកើនឡើង ២0% ក្នុងនេះ ចំណូលចរន្តកើនឡើង២0% និងចំណូលមូលធនកើនឡើង២% ។ ការកើនឡើងនៃចំណូលចរន្តជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង២0% និងចំណូលមិនមែនសារពើពន្ធ កើនឡើង១៨%។

ចំណាយថវិកាជាតិក្នុងឆ្នាំ២០១៨ អនុវត្តបាន១៦.៨២៧,៩ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤.២០៧,0លានដុល្លារ) ស្មើនឹង ៨៩% នៃផែនការ ក្នុងនោះ ចំណាយចរន្ត ១៤.0៧៦,៣ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៣.៥១៩,១លានដុល្លារ) ស្មើនឹង ៩២% នៃផែនការ និងចំណាយមូលធន ២៧៥១,៥ប៊ីលានរៀល។ បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិកើនឡើង ១៨%ក្នុងនោះចំណាយចរន្តកើនឡើង ១៦%និងចំណាយមូលធនកើនឡើង២៣%។

ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០១៨ មានអតិរេកចំនួន ៣.១២៧,៨ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៧៨១,៩លានដុល្លារ)។ ប៉ុន្តែគួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលបានឆ្លងកាត់រតនាគារជាតិតែប៉ុណ្ណោះ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

រូបិយវត្ថុ *M2* មានចំនួន៨៨៤៤៣,២ប៊ីលានរៀល កើនឡើង២៤% ធៀបនឹងឆ្នាំ២០១៧។ សមាសធាតុរូបិយវត្ថុមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ : រូបិយវត្ថុក្រៅធនាគារថយចុះពី ១១,៦% នៃM2 ក្នុងឆ្នាំ២០១៧ មក១០,៥% ក្នុងឆ្នាំ២០១៨ ឯប្រាក់បញ្ញើជារូបិយបណ្ណបរទេសកើនឡើងពី៨៣,១% ទៅ៨៤,៨%នៃM2។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៨** (% នៃរូបិយវត្ថុទូទៅ*M2*)




**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០១៧**




តារាងខាងក្រោមបង្ហាញកំណើនសូចនាកររូបិយវត្ថុធៀបនឹងឆ្នាំមុន (២០១៤-២០១៨)

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| *M2* | +២៩,៩% | +១៤,៧% | +១៧,៩% | +២៣,៨% | +២៤,០% |
| *សមាមាត្រ M2 ក្នុងផសស* | ៦៣% | ៦៧% | ៧២% | ៨០% | ៨៩% |
| *M1* | +២៩,៣% | +៦,៩% | +៧,២% | +២៩,៦% | +៨,៥% |
| *សមាមាត្រ M1 ក្នុងផសស* | ៩% | ៩,២% | ៩% | ១០,៥% | ១០,៣% |
| រូបិយវត្ថុក្រៅធនាគារ | +២៥,៦% | +៥,៤% | +៨,៩% | +២៨,២% | +១១,៥% |
| ប្រាក់បញ្ញើចរន្ត | +៦៨,៥% | +១៨,១% | -៥,៣% | +៤០,៩% | -១៣,៨% |
| រូបិយវត្ថុផ្សេងៗ | +៣០% | +១៦,១% | +១៩,៦% | +២២,៩% | +២៦,៤% |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | +១៥,៣% | +៤២,២% | +៥៤,០% | +៩,៦% | +២២,៧% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +៣០,៥% | +១៥,៣% | +១៨,៣% | +២៣,៦% | +២៦,៥% |

ក្នុងឆ្នាំ២០១៨ រូបិយវត្ថុទូទៅ*M2* មានចំនួនប្រហែល ៨៩%នៃផសស ប៉ុន្តែ**សមមាត្រ***M1* ក្នុងផសស មានត្រឹមតែ ១០,៣% ប៉ុណ្ណោះ។ ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធមានចំនួន ១០ ០៤៣ លានដុល្លារ កើនឡើង១៦% ធៀបនឹងឆ្នាំ ២០១៧។ ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅ**ធនាគារជាតិនៃកម្ពុជា** មានចំនួន៣០.៥៥៦,៣ ប៊ីលានរៀល កើនឡើង១៦,២%បើធៀបនឹងឆ្នាំមុន។ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន៨៥.០០៥,៦ប៊ីលានរៀលកើនឡើង ២៤,៥%ធៀបនឹងឆ្នាំមុន។

តារាងខាងក្រោមបង្ហាញអត្រាការប្រាក់ប្រចាំឆ្នាំ នៅធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន។

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ* ២០១៨ | *អត្រាឆ្នាំ* ២០១៧ | %∆(២០១៨/២០១៧) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,១% | ៥,៩% | ៣,៧% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៣,៨% | ១៤,៥% | -៤,៥% |

| | | | |
|---|---|---|---|
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៤២% | 0,0% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៧៣% | ១១,៦៧% | 0,៥% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៧,៩% | ១៨,0% | -0,៨% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៨% | ១៨,0% | -0,៩% |
| កម្ចីជារៀលនៅប្រាសាក់ | ១៧,0% | ១៧,៥% | -៣,0% |

### ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

**➢*កសិកម្ម:***

ផលិតផលស្រូវប្រចាំឆ្នាំ២០១៨ មានចំនួន ១០.៦៧២ពាន់តោន មានការកើនឡើង៣%ធៀបនឹងឆ្នាំ២០១៧ ដែលមានទំហំ ១០.៣៩៨ពាន់តោន។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពី ការកើនឡើងនៃផ្ទៃដីដាំដុះ ពី ៣.១៨០ពាន់ហិកតា នាឆ្នាំ២០១៧ ទៅ ៣.២៩៥ពាន់ហិកតា នាឆ្នាំ២០១៨ រីឯទិន្នផលស្រូវមានការកើនឡើងពី ៣,២៩៨ តោន/ហិកតានាឆ្នាំ២០១៧ ទៅ ៣,៣៤២ តោន/ហិកតានាឆ្នាំ២០១៨។







ក្នុងឆ្នាំ២០១៨ ផលិតផលកៅស៊ូមានចំនួន២២០,១ពាន់តោន កើនឡើង ១៣,៩% ធៀបនឹងឆ្នាំ២០១៧។ ផ្ទៃដីចៀរជ័រមានចំនួន២០១,៩ ពាន់ហិកតាកើនឡើង១៨,៧%ធៀបនឹងឆ្នាំ២០១៧ និងផ្ទៃដីដាំដុះសរុបមាន ៤៣៦,៧ ពាន់ហិចតាកើនឡើង 0,១%ធៀបនឹងឆ្នាំ២០១៧។ ផលិតកម្មនេសាទឆ្នាំ២០១៨ មានចំនួន ៩១០,២ ពាន់តោនមានការកើនឡើង ៦%ធៀបនឹងឆ្នាំ២០១៧។

**➢*ឧស្សាហកម្ម***

ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មមានចំនួន១២៧៨ រោងចក្រ ថយចុះ១៦% ធៀបនឹងឆ្នាំ២០១៧។ តារាងខាងក្រោម បង្ហាញចំនួនសរុប និងបើកថ្មី នៃរោងចក្រនៅក្រសួងឧស្សាហកម្ម។

| *ប្រភេទ* | *ចំនួន :២០១៨* | *ចំនួន:២០១៧* | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១២៧៨ | ១៥២២ | -១៦% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៧៨ | ១៥0 | +១៩% |

**➢ *រ៉ែនិងថាមពល:***

ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៩៤៨0,២ GWh កើនឡើង ២២% ក្នុងនោះ វារីអគ្គិសនីមានចំនួន៤៧៣១,៣ GWh កើនឡើង ៧៥% ធ្យូងថ្មចំនួន៣០៥៥,៨GWh ថយចុះ១៤%នាំចូលពីប្រទេសជិតខាងចំនួន១៣៥៤,0 GWh កើនឡើង ១១% និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតចំនួន៣៣៩,១ GWh កើនឡើង ១៧% ធៀបនឹងឆ្នាំ២០១៧។

**➢សំណង់ (ការអនុញ្ញាត):**

ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ២០១៨ មានចំនួន១២៣៧៨,១ពាន់ម$^{២}$ កើនឡើង៩%បើគិតជាទឹកប្រាក់ស្មើនឹង ៥៧៥៥,៣លានដុល្លារថយចុះ១៥%ធៀបនឹងឆ្នាំ ២០១៧។

| ប្រភេទសំណង់ | ពាន់ម² :២០១៨ | ពាន់ម² :២០១៧ | % Δ |
|---|---|---|---|
| លំនៅឋាន | ៥.១៨២,៨ | ៥.៨០៤,៤ | -១១% |
| ឧស្សាហកម្ម | ៨៨៤,៦ | ១.១៩៥,១ | -២៦% |
| ពាណិជ្ជកម្ម | ៣.៧០៤,០ | ៣.៧៦៣,៧ | -២% |
| ទេសចរណ៍ | ២.៦៣០,៧ | ៥៦១,៨ | +៣៦៨% |
| ... | ... | ... | ... |
| អនុញ្ញាតសរុប | ១២.៣៧៨,១ | ១១.៣៨១,៩ | +៩% |

ក្នុងការអនុញ្ញាតនេះសំណង់ដែលពេញនិយមមាន លំនៅឋាន (៤១,៩%នៃផ្ទៃក្រឡាសរុប)និងពាណិជ្ជកម្ម (២៩,៩% នៃផ្ទៃក្រឡាសរុប) ។

➢ **ការងារ:**

| ប្រភេទ | ២០១៨ (នាក់) | ២០១៧ (នាក់) | %Δ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៦.៥២៧ | ១៤.៨១១ | +១២% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២០៥.៣៥៩ | ១៩៦.០៥២ | +៥% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៣៦.៧៨៨ | ១៥០.៨១៣ | -៩% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៦៨.៥៧១ | ៤៥.២៣៩ | +៥២% |

➢ ***វិនិយោគ:*** គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. ក្នុងឆ្នាំ២០១៨

| ប្រភេទ | ២០១៨ | ២០១៧ | %Δ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៦៤៥១,៥ | ៦៣៣១,១ | +២% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៤៥៧,៧ | ៣៩៦,២ | +១៦% |
| វិស័យឧស្សាហកម្ម | ១៥៤៨,៧ | ១២៦៨,៩ | +២២% |
| (ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ៤៤២,១ | ៤៨៤,០ | -៩% |
| វិស័យទេសចរណ៍ | ១៦១២,៥ | ៣១៦៦,៦ | -៤៩% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២៨៣២,៦ | ១៤៩៩,៥ | +៨៩% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ២៥៥ | ១៨៣ | +៣៩% |
| **ចំនួនពលករ (ពាន់នាក់)** | ២៣៧,៤ | ២០១,៣ | +១៨% |

➢ ***សេវាកម្មនិងទេសចរណ៍*** **(ការចុះបញ្ជីនិងលុបចេញពីបញ្ជី)**

| ប្រភេទ | ២០១៨ (ចំនួន) | ២០១៧(ចំនួន) | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១២៤៤០ | ៥៥៧១ | +១២៣% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៤៣ | ៨៧ | +៦៤% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៦១០៩ | ៥៦៦៥ | +៨% |

➢ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ)មានចំនួន ១១១៦៩,៥ពាន់តោនកើនឡើង១០%។ ក្នុងនោះ:

| ប្រភេទ | ២០១៨ (ពាន់តោន) | ២០១៧(ពាន់តោន) | %Δ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ៣១៦២,០ | ២៧៦០,៩ | +១៥% |
| កំពង់ផែកំពង់សោម | ៧១៨៣,៧ | ៦៤៦១,២ | +១១% |
| កំពង់ផែស្រែអំបិល និងកោះកុង | ១៨៣,៩ | ១៩៤,៤ | -៥% |
| កំពង់ផែឧកញ៉ាម៉ុង | ៦៣៩,៩ | ៧០២,៤ | -៩% |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ២០១៨ | ២០១៧ | %∆ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២២៣,៨ | ២០៤,៣ | +៩,៥% |
| ក្នុងនោះទទួល | ២៨,៣ | ២៨,០ | +១,០% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១.១៩៨,៩ | ១.២៤៥,៤ | -៣,៧% |
| ក្នុងនោះទទួល | ៦៤៤,៤ | ៦៥១,០ | -១,០% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២២.២៧១,៥ | ២៧.៧១៤,៩ | -២០% |
| ក្នុងនោះហៅចូល | ៦.៦៩១,៣ | ៨.១៧០,៤ | -១៨% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៨១.៧០៧,៧ | ១០៦.៦៧២,៦ | -២៣% |
| ក្នុងនោះហៅចូល | ៨០.៥៩៣,៤ | ១០៥.៨៣០,០ | -២៤% |

➢អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍

| ប្រភេទ | ២០១៨ (ពាន់នាក់) | ២០១៧ (ពាន់នាក់) | %∆ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២០៩,២ | ២២៣,៧ | -៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៦៣៦,៧ | ៥៧១,៧ | +១១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៩.៣៧៦,៤ | ៧.៦៦៥,៧ | +២២% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ១.៩៩៥,៥ | ១.៧៥២,៣ | +១៤% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៦.២០១,១ | ៥.៦០១,៩ | +១១% |
| ✓តាមផ្លូវអាកាស | ៤.០៩៦,៩ | ៣.៣១២,៧ | +២៤% |
| ✓ តាមផ្លូវគោក និងទឹក | ២.១០៤,២ | ២.២៨៩,១ | -៨% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០១៨ មានចំនួន៦៧៨១៥,៥ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១៦.៩៥៣,៩លានដុល្លារ)កើនឡើង ២៣% បើធៀបនឹងឆ្នាំ ២០១៧ក្នុងនោះ ៖

| មានការថយចុះ | មានការកើនឡើង |
|---|---|
| គ្រាក់ទ័រនិងគោយន្ត-៣% | ប្រេងសាំង +៨% |
| ស្រូវសាលី -៦៦% | ប្រេងម៉ាស៊ូត +៥% |
| ផ្លែឈើនិងបន្លែ -៣១% | ឧស្ម័ន +២០% |
| ស្ករស-៣០% | ដែកសំណង់+២១% |
| ប្រេងឆា-៤៩% | ស៊ីម៉ង់ +២% |
| ប៊ីចេង-២% | រថយន្តទេសចរណ៍+៥% |
| | នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +៤% |
| | អនុញ្ញាតិនាំចូលក្នុងក្របខ័ណ្ឌវិនិយោគឯកជន+០,៣% |
| | អនុញ្ញាតិនាំចូលក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈ+៥០% |

**ការនាំចេញ**ឆ្នាំ២០១៨មានចំនួន៥១៥៣៣ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១២៨៨៣,២លានដុល្លារ)ស្មើនឹង៧៥,៩%នៃការនាំចូល មានការកើនឡើង១២%ធៀបនឹងឆ្នាំ២០១៦ក្នុងនោះ ៖

| ទំនិញ | %∆ធៀបនឹង-២០១៧ | ទំនិញ | %∆ធៀបនឹង-២០១៧ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | –៤៧% | ផលិតផលនេសាទ | +៤៩% |
| វាយនភណ្ឌនិងស្បែកជើង | +១៩% | កៅស៊ូ | +៥% |
| អង្ករ | –២% | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១៨នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម:

| សូចនាករ | បម្រែបម្រួលធៀបនឹងឆ្នាំ ២០១៧ |
|---|---|
| ១) ថ្លៃប្រេងសាំង | ៦,០% |
| ២) ថ្លៃប្រេងម៉ាស៊ូត | ៦,០% |
| ៣) ថ្លៃត្រីស្រស់ | ៤,០% |
| ៤) ចំណូលថវិការ ខេត្ត រាជធានី | ៥៥% |
| ៥) អគ្គីសនីផ្គត់ផ្គង់ដោយវារីអគ្គីសនី | ៧៥% |
| ៦) ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម | -១៦,០% |
| ៧) ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | -៥៣,០% |

## ៧) សេចក្តីសន្និដ្ឋាន

១) អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០១៨ នេះ ស្មើនឹង ២,៥% នៅមានកម្រិតទាប បើធៀបនឹងអត្រាគោលនយោបាយមិនឱ្យលើស ៥% និងក៏ទាបជាងឆ្នាំ២០១៧ ដែលមានអត្រា ២,៩%។ សន្ទស្សន៍ថ្លៃក្រុមម្ហូបអាហារ និងក្រុមដឹកជញ្ជូន ដែលរួមគ្នាមានទំងន់ប្រមាណ ៥៥% (៤៣% + ១២%) នៃកន្ត្រកប្រើប្រាស់សរុប ជាកត្តាចំបងដែលធ្វើឱ្យអតិផរណាឆ្នាំ២០១៨មានកម្រិតទាបបែបនេះ។ បានសង្កេតឃើញថា កំណើនថ្លៃក្រុមម្ហូបអាហារមាននិន្នាការថយចុះនាប៉ុន្មានឆ្នាំចុងក្រោយនេះ ឆ្នាំ២០១៨ មានកំណើន ២,៥% ឆ្នាំ២០១៧ មាន៣,៤% ឆ្នាំ២០១៦ មាន៥,៦% ជាដើម ដែលក្នុងនោះសាច់ ត្រីស្រស់ និងបន្លែ មានការថមថយកំណើនគួរឱ្យកត់សម្គាល់។ កំណើនក្រុមដឹកជញ្ជូនក៏មាននិន្នាការថយចុះដែរដូចជាឆ្នាំ២០១៨ មានកំណើន ២,៩% ឆ្នាំ២០១៧ មាន៤,១%។

២) ចំណូលថវិកាជាតិឆ្នាំ២០១៨ មានចំនួន ១៩ ៩៥៦ ប៊ីលានរៀល ឬ ៤,៩ ប៊ីលានដុល្លារអាមេរិច ស្មើនឹង ២០%នៃផសស ដែលប្រហាក់ប្រហែលបណ្តាប្រទេសអាស៊ានដែរ។ ក្នុងនោះ ចំណូលសារពើពន្ធ មានចំនួនប្រហែល ២,៥ ប៊ីលានដុល្លារអាមេរិច ដែលនៅតែពឹងផ្អែកខ្លាំងលើចំណូលពន្ធគយ (៥៩% នៃចំណូលសារពើពន្ធ) រីឯចំណូលពន្ធដារមានទំហំ ៤១%នៃចំណូលសារពើពន្ធ។

៣) ស្ថានភាពរូបិយវត្ថុបានបង្ហាញពីការចាក់ឬសកាន់តែជ្រៅនៃដុល្លារូបនីយកម្មនៅកម្ពុជា : ប្រាក់បញ្ញើជារូបិយបណ្ណ កើនដល់ ៨៤,៦% នៃរូបិយវត្ថុ M2 ដូច្នេះ សមាសភាពប្រាក់រៀលមានចំនួនតែ ១៥,៤% នៃ M2 ប៉ុណ្ណោះ។ គួរកត់សម្គាល់ដែរថា ក្នុងកំណើន២៤% នៃ M2 មានកំណើន M1 តែ ៨,៥% ប៉ុណ្ណោះ ឯកំណើនប្រាក់បញ្ញើជារូបិយបណ្ណស្មើនឹង ២៦,៥%។ ចំណែក ប្រាក់បញ្ញើចរន្ត (ជាប្រភេទប្រាក់រៀល) មានការថយចុះ ១៣,៨% ជាសញ្ញាថាមានតម្រូវការខ្ពស់លើប្រាក់រៀលក្នុងចរាចរ ។

៤) សំណង់អនុញ្ញាត្តមានការកើនឡើងគិតជាផ្ទៃក្រឡា ចំនួន៩% ប៉ុន្តែថយចុះជាសាច់ប្រាក់ចំនួន១៥% ជារួមដោយសារ ក្នុងឆ្នាំ ២០១៧ មានសំណង់ខ្នាតធំ១ ដែលមានទុនខ្ពស់ខ្លាំង ធ្វើឱ្យតួលេខវិនិយោគលើវិស័យសំណង់ឆ្នាំ ២០១៨ មានលក្ខណៈរមៀទម។ ជាសរុប វិស័យសំណង់នៅតែបង្ហាញភាពខ្លាំងរបស់ខ្លួន និងជាវិស័យអូសទាញមួយនៃសេដ្ឋកិច្ចកម្ពុជា។

៥) តួលេខនាំចេញអង្ករឆ្នាំ២០១៨ មានការថយចុះ ៩ពាន់តោន ធៀបនឹងឆ្នាំ២០១៧។

៦) ជារួម សេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៨ សម្រេចបានលទ្ធផលជាវិជ្ជមានមួយចំនួនគួរឱ្យកត់សម្គាល់ ដូចជា ការគ្រប់គ្រងបាននូវស្ថានភាពថ្លៃ ការគៀងគរចំណូលថវិកាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានលើកកម្ពស់ ការផ្តល់ឥណទាន និងផលិតកម្មវាយនភណ្ឌនិងស្បែកជើង បានបង្ហាញអំពីកំណើនធៀបនឹងឆ្នាំ ២០១៧។

យ៉ាងណាមិញ នៅមានបញ្ហាប្រឈមមួយចំនួនសម្រាប់ឆ្នាំខាងមុខ ដូចជា ការប្រែប្រួលនៃលំហូរទុនវិនិ-យោគនិងពាណិជ្ជកម្មអន្តរជាតិ ការនាំចេញអង្ករមានកម្រិតទាបធៀបនឹងផែនការ ។ល។

## សកម្មភាពការងារក្នុងត្រីមាសទី១ ឆ្នាំ២០១៩

កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment) ហៅកាត់ថា "កម្មវិធីRIA" ក្រោមការគ្រប់គ្រងរបស់ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត(Regulatory Executive Team - RET) នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានក្រសួង ស្ថាប័នចំនួន ១៨ ចូលរួម គឺក្រសួងពាណិជ្ជកម្ម(MoC) ក្រសួងបរិស្ថាន(MoE) ក្រសួងទេសចរណ៍(MoT) ក្រសួងរ៉ែ និងថាមពល (MoME) ក្រសួងអប់រំ យុវជននិងកីឡា(MoEYS) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MoAFF) ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(MoLVT) ក្រសួងសុខាភិបាល(MoH) ក្រសួងឧស្សាហកម្មនិងសិប្បកម្ម(MIH) ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់(MLMUPC) ក្រសួងសាធារណការនិងដឹកជញ្ជូន(MPWT) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(MEF) ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(MPTC) ក្រសួងការពារជាតិ(MND) ក្រសួងយុត្តិធម៌(MoJ) រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល(SSCA) អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា(S.G. Senate) និងក្រុមប្រឹក្សាធម្មនុញ្ញ(CC)។

កម្មវិធី RIA មានគោលបំណងពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលនៃបញ្ញត្តិកម្មតាមរយៈការដាក់ឲ្យអនុវត្តនូវគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល ដោយយកវិធីសាស្ត្រ RIA ជាឧបករណ៍បច្ចេកទេសសម្រាប់ធ្វើការវាយតម្លៃ។ ប្រព័ន្ធ RIA តម្រូវឲ្យក្រសួងនីមួយៗវាយតម្លៃលើស្មារតីឬខ្លឹមសារនៃបទប្បញ្ញត្តិដែលមានផលប៉ះពាល់អវិជ្ជមានដល់ធុរកិច្ច សង្គម និងបរិស្ថាន។ ដើម្បីធានាភាពមាំមួននៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការអនុវត្ត RIA ត្រូវធានាថា (i)ជម្រើសនីមួយៗត្រូវបានយកមកពិចារណា ដោយធានាបាននូវប្រសិទ្ធភាពរបស់បញ្ញត្តិកម្មដែលនឹងត្រូវបង្កើត (ii)បញ្ញត្តិកម្មមិនត្រូវបានធ្វើនៅពេលដែលវាបង្ហាញថាជាជម្រើសមិនល្អ (iii)មានការពិគ្រោះយោបល់ជាសាធារណៈក្នុងកម្រិតទទួលយកបាន។

ក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ២០១៩ ក្រុម RET ក.ស.វ បានធ្វើសកម្មភាពដែលចែកចេញជាបីផ្នែកធំៗ (ក)ការប្រជុំផ្តល់យោបល់លើរបាយការណ៍RIA របស់ក្រសួង (ខ)ការផ្សព្វផ្សាយ (គ)ការប្រជុំដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងកម្មវិធីដែលលម្អិតដូចខាងក្រោម៖

**ក-** ការប្រជុំដើម្បីផ្តល់យោបល់លើរបាយការណ៍ RIA របស់ក្រសួង

ព្រឹកថ្ងៃសុក្រ ៥រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ នៅបន្ទប់១៣១ អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ម៉ិច សុខា** សមាជិក និងជាអគ្គលេខាធិការរងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានដឹកនាំប្រជុំក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(ក្រុមRIA) របស់ ECOSOCC ជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដឹកនាំដោយលោក **ចាន់ សុសុវ៉ាន់ត្រា** អគ្គនាយករងកិច្ចការទូទៅ និងជាប្រធានក្រុមការងារ RIA ដើម្បី



ពិនិត្យផ្តល់យោបល់ចុងក្រោយលើរបាយការណ៍វាយតម្លៃបឋមលើផលប៉ះពាល់លើសេចក្តីព្រាងប្រកាសស្តីពីវិធានសម្រាប់គ្រប់គ្រង និងដំណើរការសហគ្រាសសិប្បកម្មផលិតទឹកពិសាដប។

នៅព្រឹកថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស .២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ នៅបន្ទប់១៣១ អគារមិត្តភាពនៃទីស្តី-ការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ម៉ិច សុខា** សមាជិក និងជាអគ្គលេខាធិការរងECOSOCC និងជាអនុ-ប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិ-យុត្ត បានដឹកនាំប្រជុំក្រុមជំនាញការងារ RIA របស់ ECOSOCC ជាមួយក្រុមការងារ RIAក្រសួងការ-ពារជាតិ ដែលដឹកនាំដោយ ឧត្តមសេនីយ៍ទោ **វណ្ណា ហ៊ុច** នាយករងនៃនាយកដ្ឋាននីតិកម្ម និងជាអនុ-ប្រធានRIA ដើម្បីពិភាក្សាកែសម្រួលលើរបាយ-ការណ៍វាយតម្លៃបឋមលើផលប៉ះពាល់នៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យស្តីពីការរៀបចំយន្តការគ្រប់គ្រងកម្រិតថ្នាក់ និងកំណត់ប្រាក់កម្រៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ។

បន្ទាប់មកទៀតនៅរសៀលថ្ងៃសុក្រ ១១ កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានប្រចាំការក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត(RET) បានដឹកនាំសមាជិក ECOSOCC ប្រជុំជាមួយក្រុម RIAរបស់ក្រសួងការពារជាតិ ដែលដឹកនាំដោយឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ម សុផាត** នាយកនៃនាយកដ្ឋាននីតិកម្ម និងជាប្រធានក្រុម RIA ក្រសួងការពារជាតិ ដើម្បីពិនិត្យផ្តល់យោបល់លើរបាយការណ៍វាយតម្លៃបឋមលើផលប៉ះពាល់នៃ



សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យលេខ២២២ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំយន្តការគ្រប់គ្រង កម្រិតថ្នាក់ និងកំណត់ប្រាក់កម្រៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ។

**ខ-** ការងារផ្សព្វផ្សាយកម្មវិធី RIA

ចាប់ពីថ្ងៃទី២៥ ២៦ និង២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដឹកនាំដោយឯកឧត្តម **ឃឹម ណុលសន** អនុ-ប្រធានប្រចាំការ ក.ស.វ. បានផ្សព្វផ្សាយកម្មវិធី និងវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(វិធីសាស្ត្រRIA) ជូនដល់សមាជិក ក.ស.វ. ទាំងអស់ដើម្បីធ្វើបច្ចុប្បន្នភាព និងយល់ដឹងបន្ថែមអំពីវិធីសាស្ត្រ RIA ក្នុងកម្មវិធីនេះមានការពិភាក្សាអំពីការបង្កើតក្រុម RIA របស់ ក.ស.វ. ដើម្បីឲ្យមាននិរន្តរភាពក្នុងការអនុវត្ត និងពិភាក្សាផ្លាស់ប្តូរយោបល់ ដើម្បីរៀបចំបញ្ជីត្រួតពិនិត្យ (Check List) សម្រាប់សមាជិក ក.ស.វ. ប្រើប្រាស់



ដើម្បីជាជំនួយស្មារតីក្នុងការត្រួតពិនិត្យលើរបាយការណ៍RIAនៅពេលក្រសួងភ្ជាប់មកជាមួយនូវសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

**គ-** ការងារត្រួតពិនិត្យនិងគ្រប់គ្រងកម្មវិធី

រសៀលថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ នៅបន្ទប់២០៤ អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានប្រចាំការនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានដឹកនាំប្រជុំជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលទើបនឹងកែសម្រួលថ្មី ដែលដឹកនាំ ឯកឧត្តម **ឡោ រស្មី** អនុរដ្ឋលេខាធិការ និងជាប្រធានក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីស្វាគមន៍ក្រុមថ្មី និងពិភាក្សាអំពីកិច្ចការដែលនឹងត្រូវអនុវត្តបន្តក្នុងឆ្នាំ២០១៩នេះ។




ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានចូលរួមអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessment -RIA) នៅដំណាក់កាលទី២ ក្នុងឆ្នាំ២០១៤ បន្ទាប់ពីក្រសួងចំនួន៤ ដំបូងដែលចូលរួមអនុវត្តគម្រោងសាកល្បងតាំងពីឆ្នាំ២០១១ មានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ និងអតីតក្រសួងឧស្សាហកម្មរ៉ែ និងថាមពល។ លទ្ធផលនៃការអនុវត្តកម្មវិធី RIA របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានដូចខាងក្រោម៖

១-បានបណ្តុះបណ្តាលធនធានមនុស្សសរុប ១៦លើក មានអ្នកចូលរួមសរុប ១០២រូប។

២-ការរៀបចំរបាយការវាយតម្លៃបឋមលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តចំនួន ២ គឺរបាយការណ៍វាយតម្លៃពេញលេញចំនួន ១ និងរបាយការណ៍វាយតម្លៃបឋម ១ ទៀតកំពុងបន្ត។

៣-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយចំនួន ២លើក មានអ្នកចូលរួមសរុប២៩០រូប។



នៅព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានប្រចាំការ ក.ស.វ. និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងឯកឧត្តម **ម៉ិច សុខា** សមាជិក និងជាអគ្គលេខាធិការរង ក.ស.វ. និងជាអនុប្រធាន

អចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានប្រជុំជាមួយក្រុមបេសកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មាន Ms. Jhelum Tini Thomas, Senior Public Management Specialist និង Ms. Evelyn Talja, Associate Project Officer ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារ ព្រមទាំងភាពប្រឈម និងផែនការដែលត្រូវអនុវត្តបន្ត បន្ទាប់ពីជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវបានបញ្ចប់ត្រឹមខែមិថុនា ឆ្នាំ២០១៩។

បេសកកម្មរបស់ ADB បានកោតសរសើរដល់ក្រុម RIA របស់ ECOSOCC ដែលបានដើរតួនាទីជាអង្គភាពទទួលបន្ទុកជាអ្នកបណ្តុះបណ្តាល ផ្តល់យោបល់ និងផ្សព្វផ្សាយដល់ក្រសួងស្ថាប័ន ១៨ ដែលចូលរួមអនុវត្ត RIA ទទួលបានលទ្ធផលល្អៗគួរឲ្យកត់សម្គាល់។ ADB នឹងពិចារណាលើលទ្ធភាពផ្សេងៗដើម្បីជួយលើការងារអនុវត្ត RIA ប៉ុន្តែចំពោះជំនួយបច្ចេកទេស(TA) លេខ ៨៨៣៤ នឹងត្រូវបញ្ចប់ត្រឹមខែមិថុនា ឆ្នាំ២០១៩ ព្រោះTAទាំងអស់ដែលបានកំណត់កាលបរិច្ឆេទបិទរួចហើយនឹងត្រូវធ្វើតាមកាលវិភាគទាំងអស់គ្នា មិនថាតែកម្ពុជាទេ។

កិច្ចការចម្បងៗបំផុតក្នុងឆមាសទី១ ឆ្នាំ ២០១៩ នេះគឺបន្តការផ្សព្វផ្សាយបណ្តុះបណ្តាល ជួយឧបត្ថម្ភដល់ក្រសួងស្ថាប័នក្នុងការរៀបចំរបាយការណ៍ RIA រួមទាំងការចុះសិក្សាប្រមូលទិន្នន័យសម្រាប់ធ្វើការវិភាគ នឹងផ្តល់ឧបករណ៍ការិយាល័យមួយចំនួនចាំបាច់បំផុត ហើយជ្រើសរើស IT Expert ដើម្បីកសាងប្រព័ន្ធឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗក្នុង Intranet and website ECOSOCC ហើយនឹងជួយផ្តល់ទីប្រឹក្សា(Resource person) សម្រាប់សិក្សាកែសម្រួលសៀវភៅណែនាំស្តីពីRIA និងទម្រង់គោលការណ៍ណែនាំ RIA (RIA Template Guideline) ផងដែរ។



ថ្ងៃព្រហស្បតិ៍ ១០កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស .២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ នៅបន្ទប់១៣១ អគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ម៉ិច សុខា** សមាជិក និងជាអគ្គលេខាធិការរងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) អនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានដឹកនាំប្រជុំក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(ក្រុមRIA)របស់ ECOSOCC ជាមួយក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយ លោក **ម៉ុង វី** អនុប្រធាននាយកដ្ឋាននីតិកម្ម និងជាអនុប្រធានក្រុមការងារ RIA ដើម្បីពិនិត្យរៀបចំផែនការសកម្មភាពជាក់ស្តែងការងារ RIA របស់ MoEYS សម្រាប់អនុវត្តក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០១៩នេះ។៚



## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែមករា ឆ្នាំ២០១៩ |
|---|---|---|
| ១ | ០២/០១/១៩ ម៉ោង០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីពិភាក្សាការងាររៀបចំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅផែនការឆ្នាំ២០១៩ ព្រមទាំងបញ្ហាផ្សេងៗ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០៧/០១/១៩ ម៉ោង០៦:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤០ ទិវាជ័យជម្នះ ៧មករា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋ-មន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅពហុកីឡដ្ឋានជាតិអូឡាំពិក។ |
| ៣ | ០៨/០១/១៩ ម៉ោង០៧:០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីបុណ្យខួបលើកទី៤០ នៃទិវាជ័យជម្នះ ៧មករា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅមុខសាលមហោស្រព ខេត្តតាកែវ។ |
| ៤ | ១១/០១/១៩ ម៉ោង០៨:៣០នាទី | ដឹកនាំប្រជុំរួមផ្ទៃក្នុង ស្ដីពីការវិវត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១១/០១/១៩ ម៉ោង១៧:០០នាទី | ចូលរួមក្នុងពិធីជួបជុំរវាង សម្ដេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអ្នកសារព័ត៌មានក្នុងស្រុកលើកទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៦ | ១៤/០១/១៩ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងទី៣ ប្រវែង ៥២,៩៨៣គ.ម ពីសង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (ផ្លូវជាតិលេខ៤) គ.ម ១៤+១០៥ ទៅដល់ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល (ផ្លូវជាតិលេខ១) គ.ម ២៤+៨៤០ ក្រោមហិរញ្ញប្បទានពីរដ្ឋាភិបាល នៃសាធារណ-រដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិកណ្ដាល សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ |
| ៧ | ១៥/០១/១៩ ម៉ោង១៤:០០នាទី | ចូលរួមក្នុងពិធីបិទការប្រកាសក្រុមប្រឹក្សាវប្បធម៌អាស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ និងមជ្ឈមណ្ឌលពិព័រណ៍សុខាសៀមរាប។ |

| | | |
|---|---|---|
| ៨ | **១៥/០១/១៩ ម៉ោង១៧:១៥នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសក្រុមប្រឹក្សាវប្បធម៌អាស៊ីជាផ្លូវការ និងពិធីលៀងសាយភោជន៍ជូនគណៈប្រតិភូអន្តរជាតិ នៅខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះលានជល់ដំរី ខេត្តសៀមរាប។ |
| ៩ | **២៣/០១/១៩ ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំចង្អៀត ដើម្បីពិនិត្យលើសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្នើសុំគោលការណ៍ធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **២៤/០១/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីមីទ្ទិញអបអរសាទររំលឹកខួបលើកទី២០ឆ្នាំ ថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោក (ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៩ - ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅបញ្ជាការដ្ឋាកងទ័ពជើងគោក ផ្លូវជាតិលេខ៤ ភូមិអង្គ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ |
| ១១ | **៣០/០១/១៩ ម៉ោង១៦:៣០នាទី** | ចូលរួមប្រជុំ ដើម្បីពិភាក្សាលើការងារចាំបាច់ចំពោះមុខមួយចំនួន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី៕ |

| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែកុម្ភៈ ឆ្នាំ២០១៩** |
|---|---|---|
| ១ | **០៦/០២/១៩ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ទេសចរណ៍ពិសិដ្ឋ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | **០៧/០២/១៩ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | **០៧/០២/១៩ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យនិងពិភាក្សាលើខ្លឹមសារជារួមនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់ទេសចរណ៍ពិសិដ្ឋ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | **១៨/០២/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | **១៨/០២/១៩ ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំចង្អៀត ដើម្បីពិភាក្សាលើស្ថានភាពវិវត្ត និងបញ្ហាប្រឈមក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ពាក់ព័ន្ធនឹងករណីកិច្ចដំណើរការនីតិវិធីក្នុងការព្យួរបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធក្រោមកម្មវិធី EBA នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៦ | **២០/០២/១៩ ម៉ោង០៦:៣០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធី សំណេះសំណាលជាមួយកម្មករនិយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិព្រៃរកា ឃុំធកឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល។ |
| ៧ | **២៥/០២/១៩ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយសក្នុង "ទិវាជាតិទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩" ក្រោមប្រធានបទ "ទីក្រុងស្អាត ទីក្រុងផ្តល់ភាពកក់ក្តៅ" អមជាមួយ "ពិធីប្រគល់ជ័យលាភីរង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍លើកទី៣" និង "ជ័យលាភីបដិសណ្ឋារកិច្ចល្អច្រកទ្វារអន្តរជាតិលើកទី២ និងជ័យលាភីបង្គន់សាធារណៈកម្ពុជាលើកទី១" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខារ៉េស៊ីដង់ភ្នំពេញ ។ |
| ៨ | **២៦/០២/១៩ ម៉ោង១១:០០នាទី** | ចូលរួមក្នុងកម្មវិធីជប់លៀងជូន ឯកឧត្តម **ង្វៀន ហ្វ៊ូជុង** អគ្គលេខាធិការគណបក្សកុម្មុយនីស្ត និងជាប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ |
| ៩ | **២៧/០២/១៩ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦ នៃស្រុកព្រៃកប្បាស ដើម្បីរៀបចំកិច្ចសហការសម្រាប់កម្មវិធីពិនិត្យ និងព្យាបាលជំងឺឥតគិតថ្លៃជូនប្រជាពលរដ្ឋ របស់សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) សហការជាមួយអង្គការមូលនិធិពុទ្ធសាសនាធីជិកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី៕ |



# ពន្យល់ពាក្យ

**១-កម្មសិទ្ធិបញ្ញា** បណ្ដាប្រភេទនៃទ្រព្យសម្បត្តិដែលផ្ដើមចេញពីការបង្កើត ដោយគំនិតនិងបញ្ញារបស់មនុស្ស ហៅថាសិទ្ធិជាម្ចាស់លើទ្រព្យសម្បត្តិខាងបញ្ញា។ សន្និសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPC) បានរាប់ស្នាដៃជាច្រើន ដូចជាស្នាដៃសិល្បៈ អក្សរសាស្ត្រ វិទ្យាសាស្ត្រ ការសម្ដែងសិល្បៈ ការប្រគំតន្ត្រី ហ្វូណូក្រាមនិងទូរផ្សាយ ការបង្កើតថ្មី គំនូរឧស្សាហកម្ម ម៉ាក ពាណិជ្ជនាម គំនូរប្លង់...។ Eng. intellectual property rights

**២-បរិយាបន្នកម្ម** សេដ្ឋ. វិធានការ ឬគោលនយោបាយ ដែលរាប់បញ្ចូលឬផ្ដល់លទ្ធភាពដល់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ពីដំណើរការនៃការអនុវត្តគម្រោង កម្មវិធី ឬគោលនយោបាយ។ Eng. inclusiveness

**៣-បរិស្ថានបៃតង** បរិ. ការអភិវឌ្ឍស្អាត ការមិនបំពុលបរិស្ថានក្នុងការថែរក្សាគុណភាពទឹក គុណភាពដី និងគុណភាពខ្យល់ សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី ការធានាបាននូវសុវត្ថិភាពចំណីអាហារ ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ ធនធានទឹកជាអាទិ៍ប្រកបដោយនិរន្តរភាព ការប្រើប្រាស់ដីប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពសាធារណៈដែលជាកត្តាចម្បងដើម្បីលើកស្ទួយសេដ្ឋកិច្ចបៃតងឱ្យមានតុល្យភាពទៅនឹងចីរភាពបរិស្ថាន សង្គមនិងវប្បធម៌។ Eng. green environment

**៤-មត៌ក** ក្រមរដ្ឋ. ទ្រព្យសម្បត្តិជាកេរទាំងឡាយដែលបុគ្គលម្នាក់(មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់។ Eng. estate/heritage

**៥-របាំងធុរកិច្ច** សេដ្ឋ. កត្តារាំងឬឧបសគ្គដល់អង្គភាពអាជីវកម្មក្នុងការចូលទីផ្សារ ឬចេញពីទីផ្សារ។ កត្តទាំងនេះមានដូចជា ការចំណាយចាប់ផ្ដើមអាជីវកម្ម ថ្លៃដើមផលិតកម្ម លក្ខខណ្ឌច្បាប់និងបទប្បញ្ញត្តិ ការប្រកួតប្រជែង កម្មសិទ្ធិបញ្ញា កម្រិតបច្ចេកវិទ្យាជាដើម។ Eng. business barrier

**៦-របាំងមិនមែនពន្ធ** សេដ្ឋ. កត្តារាំង ឬឧបសគ្គក្រៅពីពន្ធ ដែលរឹតត្បិតការធ្វើពាណិជ្ជកម្មអន្តរជាតិ មានដូចជាបទដ្ឋានស្តង់ដាគុណភាព អនាម័យ និងបរិស្ថាន ការបំពេញបែបបទគយ កូតាជាដើម។ Eng.non-tariff barriers

**៧.រហស្សនាម** វប្ប. ឈ្មោះដែលបុគ្គលណាម្នាក់ ឬក្រុមណាមួយ ប្រើសម្រាប់ហៅក្រៅពីឈ្មោះពិតរបស់ខ្លួន ក្នុងការបង្កើតស្នាដៃឬធ្វើសកម្មភាពក្នុងអក្សរសិល្ប៍ឬសិល្បៈជាដើម។ Eng. pseudonym

**៨-សង្គមធម៌** មែកធាងនៃអរិយធម៌ដែលទ្រទ្រង់ការរស់នៅនិងការបណ្ដុះបណ្ដាលតាមរយៈគ្រឿងសម្ភារៈ ប្រដាប់ប្រើប្រាស់ វិធីបច្ចេកទេស ការបង្កើតផលិតផល ការរៀបចំសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ...។ Eng. social affairs

**៩-សូចនាគោល** ១.អថេរដែលអាចវាស់វែងសម្រាប់ជាមូលដ្ឋាន ឬយោងក្នុងការវាយតម្លៃការបំពេញការងាររបស់ស្ថាប័នមួយ។ ២.ចំណុចគោលអាចទាញចេញពីបទពិសោធផ្ទៃក្នុងរបស់ស្ថាប័នមួយឬច្រើន ដែលស្ថាប័នផ្សេងៗត្រូវការ ឬជាតម្រូវការផ្នែកច្បាប់ ដើម្បីវាស់វែងភាពប្រែប្រួលនៃប្រតិបត្តិការក្នុងរយៈពេលមួយ។ Eng. benchmark

*ដកស្រង់ចេញពីសទ្ទានុក្រមបច្ចេកសព្ទ*

# កម្លាំងសាមគ្គីខ្មែរសម័យអង្គរ

តាមការសិក្សាស្រាវជ្រាវរបស់យើង យើងអាចសន្និដ្ឋានបានថា កម្លាំងសាមគ្គីខ្មែរសម័យអង្គរ កើតឡើងដោយសារការគោរពលទ្ធិព្រះទេវរាជា ដែលព្រះបាទជ័យវរ័ន្មទី២ បានបង្កើតឡើងនៅដើមសតវត្សទី៩ គឺនៅគ.ស.៨០២ នៅពេលដែលព្រះអង្គឡើងគ្រងរាជពេញលក្ខណៈជាព្រះរាជា។

យើងបានដឹងថា នៅក្នុងចំណែកទី២ នៃសតវត្សទី៨ ប្រទេសខ្មែរស្ថិតក្នុងសភាពអាប់អួរខ្លាំង អស់រយៈពេលប្រហែលជាង៥០ឆ្នាំ។ ដំណើរប្រវត្តិសាស្ត្រខ្មែរមានសភាពមិនប្រាកដ ដោយយើងគ្មានឯកសារជាភស្តុតាង។ ចំណារលើថ្មនៅពេលនោះ និងក្នុងរជ្ជកាលព្រះបាទជ័យវរន្មទី២ ក៏គ្មានទាល់តែសោះ។ ព័ត៌មានខ្លះៗដែលជួយបំភ្លឺយើងនៅសម័យនោះបានឈ្មួញជាតិអារ៉ាប់កត់ត្រាទុក ដោយបានទទួលបន្តពីប្រទេសជ្វា (Java) ដែលស្ថិតនៅក្រោមការត្រួតត្រានៃសន្តតិវង្សសៃលេន្ទ្រ (Sailendras) ។ អ្នកជំនួញជាតិអារ៉ាប់មានឈ្មោះថា ស៊ូឡៃម៉ាន់ (Sulayman) បានសរសេរទុកព័ត៌មាននេះ នៅគ.ស.៨៥១ ដូចតទៅ៖

“ ... មានស្តេចក្មេងម្នាក់គ្រងរាជ្យនៅប្រទេសកម្ពុជា មានចិត្តក្តៅក្តៅគ្លើនមើលងាយព្រះមហារាជានៃប្រទេសសាបា (Zabag) ដែលគ្រប់គ្រងកោះរាប់ពាន់ក្បែរជ្រោយម៉ាឡាកា (Malacca) ។ ព្រះរាជាខ្មែរអង្គនេះបានប្រាប់មេទ័ពនាម៉ឺនសព្វមុខមន្ត្រីខ្មែរជាញឹកញយថា ខ្លួនមានប្រាថ្នាចង់ឃើញក្បាលនៃព្រះមហារាជានៃប្រទេសសាបា នៅលើជើងពានចំពោះមុខខ្លួន។ល។ ... ស្តេចខ្មែរដែលបន្ទុបលើបល្ល័ង្គ បាននាំសួយសារអាករទៅប្រទេសសាបា និងបែរមុខគោរពទិសនោះរាល់ៗថ្ងៃ... ”។ (ដកស្រង់ចេញពីសៀវភៅដែលមានចំណងជើងថា L’Empire Sumatranais du Çrivijaya vol...20 pp.56-61 ច្បាប់បកប្រែរបស់លោក G. Ferraud)។

ព្រះបាទជ័យវរ័ន្មទី២ ប្រហែលជាបានជ្រកនៅសាបា (Zabag) ជាច្រើនឆ្នាំ ក្នុងឋានៈខ្លួនជាញាតិនៃព្រះរាជាខ្មែរ។ ទ្រង់ត្រលប់មកវិញប្រហែលជាគ.ស.៧៩៨ មកជ្រកនៅឯសម្ភុបុរ (Sambhupura) ក្នុងស្រុកសម្បូរ ខេត្តក្រចេះ ដែលពេលនោះជាភូមិភាគមួយគ្រប់គ្រងដោយញាតិដ៏ជិតស្និទ្ធរបស់ព្រះអង្គ។ ក្រោយនោះបន្តិច ព្រះអង្គមកគង់នៅឥន្ទ្របុរ (Indrapura) ទំនងត្រង់បន្ទាយព្រៃនគរ ក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់-ចាម។ នៅពេលដែលបានប្រមូលអំណាចគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជារួចហើយ ព្រះអង្គក៏បានឲ្យគេរៀបចំពិធីរាជាភិសេកតាមលក្ខណៈច្បាប់នៃប្រទេស។

ក្នុងពិធីរាជាភិសេកនេះព្រះបាទជ័យវរ័ន្មទី២ បានរៀបចំបង្កើតលទ្ធិគោរពមួយឈ្មោះថា “ព្រះទេវរាជា” ជាភាសាខ្មែរបុរាណថា ព្រះកម្រងតេងជគតតរាជ្យ (ស្តេចដែលជាម្ចាស់នៃចក្រវាល Dieu-Roi ឬ God-King)។ ព្រះអង្គបានអញ្ជើញព្រាហ្មណ៍ព្រឹទ្ធាចារ្យម្នាក់ឈ្មោះ ហិរាណ្យទាម (Hiranjadama) ពីជនបទឲ្យមករៀបពិធីនេះ ដែលជានិមិត្តរូបនៃការប្រកាសឯករាជ្យនៃប្រទេសកម្ពុជាពីជ្វា។ ពិធីប្រកក់ប្រសិទ្ធិនេះឯង ជាពិធីរាជា-ភិសេកនៃព្រះបាទជ័យវរ័ន្មទី២ ជាស្តេចចក្រពត្តិ (ចក្រវាទីន Cakravartin)ផង។

ព្រាហ្មណ៍ឈ្មោះ ហិរាណ្យទាម បានសូត្រមន្តអាគមចេញពីគម្ពីរបួន ដែលមានឈ្មោះថា៖ វិនាសសិខ នយោត្តរ សម្មោហ និងសិរច្ឆេទ ក្នុងការរៀបចំលទ្ធិព្រះទេវរាជានេះ ហើយបានបង្រៀនគម្ពីរទាំងបួននោះ ដល់ព្រាហ្មណ៍ បុរោហិត សិវកៃវល្យ (Çivakaivalya) ដែលជាបុរោហិតរបស់ព្រះបាទជ័យវរ័ន្មទី២ ថែមទាំបានបង្រៀនពិធីបូជាព្រះទេវរាជាដែលត្រូវធ្វើរៀងរាល់ថ្ងៃទៀតផង។ មុននឹងចង្អុលបង្ហាញនូវអ្វីដែលជាកម្លាំងសាមគ្គីខ្មែរនៅសម័យអង្គរ យើងនឹងលើកយកគ្រឹះឬមូលដ្ឋានរបស់សាមគ្គីខ្មែរមកបកស្រាយជាមុនសិន បន្ទាប់

មកយើងនឹងបង្ហាញជូននូវលទ្ធផល គឺកម្លាំងសាមគ្គីខ្មែរដែលកើតឡើងដោយសារតែមូលដ្ឋាននេះ។

ក្នុងចំណោមគម្ពីរទាំងបួនដែល ហិរម្យទាម សូត្រប្រកក់ប្រសិទ្ធិបង្កើតជាលទ្ធិទេវរាជនោះ លោក P.C. Bagchi ប្រវត្តិវិទូជាតិឥណ្ឌាបានឃើញឈ្មោះគម្ពីរបី គឺ នយោត្តរ សម្មោហ និងសិរច្ឆេទ នៅក្នុងគម្ពីរតន្ត្រ (Tantra) មួយឈ្មោះ Brahmayámalá នៅក្នុងបណ្ណាល័យនៃព្រះរាជវាំងប្រទេសណេប៉ាល់ តែឈ្មោះគម្ពីរវិនាសសិខមិនមានក្នុងគម្ពីរនោះទេ។ សិលាចារិកស្តុកកក់ធំ (Sdok Kok Thom) ផ្នែកភាសាសំស្រ្កឹតបានហៅគម្ពីរទាំងបួននោះថា " មុខបួននៃ Tumburu " ដកស្រង់ចេញពី BEFEO,X.L(Z)P.670។ ប្រវត្តិវិទូជនជាតិឥណ្ឌាដដែលនោះបានចង្អុលបញ្ជាក់ថា Tumburu គឺព្រះសិវៈហ្នឹងឯង។ ឯគម្ពីរខាងទ្រឹស្តីវិចិត្រសិល្បៈឥណ្ឌា ដែលមានចំណាស់ជាងគេឈ្មោះ Visnudhar mouttara បានប្រាប់យើងយ៉ាងច្បាស់ថា ត្រូវធ្វើឲ្យមានមុខបួនដូចសិវៈ(Siva) ជិះនៅលើគោឧសភរាជ។ មុខទាំងបួននៃ Tumburu ជានិមិត្តរូបនៃអំណាចនៅក្នុងទិសទាំងបួន បើដូចនេះ គឺថាមានការទាក់ទងទៅនឹងគោលគំនិតដែលជាស្តេចចក្រពត្តិផ្សព្វផ្សាយអំណាចនៅក្នុងទិសទាំងបួន។ តាមការសន្និដ្ឋានរបស់យើង យើងនៅតែយល់ថាលទ្ធិទេវរាជាខ្មែរនេះឯង ដែលជាគ្រឹះឬជាមូលដ្ឋាននៃកម្លាំងសាមគ្គីខ្មែរសម័យអង្គរ។ នៅពេលដែលព្រហ្មញ្ញសាសនាត្រូវបានគេនាំចូលមកប្រទេសខ្មែរ រហូតមកដល់ដើមសតវត្សទី៩ ប្រជាពលរដ្ឋរាប់អានគោរពត្រឹមតែព្រះសិវៈលិង្គ ដែលជានិមិត្តរូបនៃព្រះសិវៈ។ ក្នុងការគោរពព្រះទេវរាជា ព្រះរាជាគ្រងរាជ្យជាចំណែកមួយនៃទេវៈ។ ការធ្វើពិធីគោរពបូជា (ព្រះសិវៈ)នេះ គឺជាការគោរពបូជាព្រះរាជាជាមួយផង។ ដូចនេះព្រះរាជាគឺជាទេវៈ ឯទេវៈគឺជាព្រះរាជាខាងផ្លូវនយោបាយ សេដ្ឋកិច្ច ដែលជាកិច្ចការផ្ទៃក្នុងក៏ដូចជាកិច្ចការនយោបាយក្រៅប្រទេសដែរ។ បើព្រះរាជាបញ្ហាបែបណារាជបញ្ជានោះក៏ជារបស់ទេវៈផងដែរ។ អំណាចអាណាចក្របានប្រែកាឡៃជាអំណាចទេវៈ។ ការប្រព្រឹត្តតាមបញ្ជាបានត្រូវនាំមកនូវបុណ្យកុសលទៅវិញ។ នេះជាកម្លាំងយ៉ាងខ្លាំងមួយដែលប្រវត្តិសាស្រ្តធ្លាប់បានឃើញ ដូចជាៈ

នៅសម័យសង្រ្គាមលុកលុយរបស់អ្នកកាន់សាសនាមហាម៉ត់ រាជវង្សកាលីហ្វា (Caliphas) នៅគ.ស. ៦៣២ ក្នុងនាមនៃសាសនារបស់ខ្លួន បានវាយលុកនៅគ្រប់ទិសតំបន់ ខាងកើតទល់នឹងឥណ្ឌា ខាងលិចទល់នឹងប្រទេសអេស្ប៉ាញ។

នៅប្រទេសខ្មែរក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២និងទី៣ ដែនដីខ្មែរបានរីកទូលំទូលាយ ផ្នែកខាងជើងទល់នឹងណាននៅ (Nan Chao) ខេត្តយុនណាន (Yunnan) ប្រទេសចិន ផ្នែកខាងត្បូងទល់នឹងទន្លេមេគង្គ ផ្នែកខាងលិចនិងខាងកើតមិនត្រូវបានគេបញ្ជាក់ក្នុងកំណត់ហេតុរបស់ចិនទេ។

កម្លាំងសាមគ្គីដែលកើតឡើងដោយសារលទ្ធិទេវរាជា មានកម្រិតខ្លាំងឡើងៗក្នុងរជ្ជកាលស្តេចបន្តបន្ទាប់មកទៀត[១]។

*ដោយបណ្ឌិតសាស្រ្តាចារ្យ អ៊ីវ ថុង*

---

[១] *អត្ថបទនេះមានតនៅលេខក្រោយទៀត។*

## ពាក្យកាព្យក្រមង៉ុយប្រដៅសិស្ស

(បទពាក្យ៧)

មនុស្សយកពាក្យគេមកទន្ទេញ បញ្ចេញយ៉ាងពេញត្រពងមាត់
អ្នកផងស្តាប់ភ័ន្តស្មានជាស្ទាត់ តែខ្លួនវាអត់កុយជាអើត។
នេះហើយគេហៅមនុស្សជាងពាក្យ ងោកងាកអាត្មាថាអញឆើត
រង្វះមាត់ហែកលៀនភ្នែកស្លើត ចំអើតភោរភាវបំភ័ន្តគេ។
អាណុបជឿតាបាកុំគ្រាប់ កុំយកតម្រាប់ខុសច្បាប់ទេ
បើស្តាប់មនុស្សពាលដែលផ្ទាលគេ ស្តាប់គេវាយធំពិរោះជាង។
សាស្ត្រាកេរ្តិ៍កាលឬច្បាប់ក្រម ចៅខំប្រឹងមើលកុំរេះរាង
បំរើគ្រូបាណាអានាង ជាជាងទន្ទេញកាកសំណៅ។
បើមានសំណាងទៅថ្ងៃមុខ ចាំទុកពាក្យតាប្រាប់កូនចៅ
កុំឲ្យវាប្រើប្រាជ្ញកម្លៅ គេដៅមារយាទដល់ម៉ែឪ។
អ្នកស្រែត្រូវតែចេះការស្រែ ចេះថែរក្សាពូជធារស្រូវ
ទើបពេញជាចេះដឹងខុសត្រូវ ម៉ែឪគ្រាន់បានស៊ីដោយសារ។
កុំអាងកំប៉ិចបន្តិចពាក្យ ជ្រោកជ្រាករាក់ជ្រៅក្រៅធម៌អាថ៌
ត្រូវចៅចៀមខ្លួនស្ងួនរោហារ មើលការគួរនឹងរូបសម្បត្តិ។
អ្នកចេះខ្មាស់អៀនបានរៀនចប់ បើគប់ប្រសព្វប្រសើរក្តាត់
ត្រង់ពាលជាងពាក្យត្រូវប្រយ័ត្ន អាចកាត់ប្រយោជន៍ឲ្យឃ្លាតឆ្ងាយ។
ចៅអឿយចៅសេកដេកសំកុក ចាំស៊ីចាំចុកស្រណុកកាយ
ម្ហឹងហើយបើចេះកុំឧបាយ លែបខាយសំដីឲ្យគេស្អប់។
មនុស្សណាគេចេះគេខ្មាសល្ងង់ មនុស្សលិចកញ្ជង់គ្មានដឹងដប់
មនុស្សណាចិត្តស្អាតគ្មានគេស្អប់ មនុស្សណាឡិចឡប់មិនរួចខ្វល់។
តែចិត្តស្អប់មនុស្សបន្ទុះភ្លាម ញ៉ីរថ្លាមរណ្តំឲ្យគេស្គាល់
បន្តិចកម្លៅខ្លួនគ្មានសល់ មនុស្សដឹងមិនដល់កោតអស់ចិត្ត។
កុំគ្រាប់មាន់ព្រៃចោលសំបុក កំចាយមាន់ស្រុកពីស្ពានស្អិត
កុំគ្រាប់មនុស្សពាលទុច្ចរិត អាចនឹងនាំចិត្តឲ្យជួជង។
តែមិនស្តាប់តាតិចស្តាយក្រោយ តាឲ្យដំបូន្មានគ្មានឆ្គង
ពាក្យតានេះកូវត្រូវគន្លង ទាក់ទាញត្របាញ់ឆ្ងាញ់ស្តាប់ណាស់៕

មិនគឺតាអ្នកអំណួតប្រាណ ផ្ទឹមច្បាប់បុរាណលោកជាន់ចាស់
សោះឡើយអាណុបស្តាប់ឲ្យច្បាស់ អាណិតឯងណាស់ក៏ថាទៅ។
ដ្បិតតាធ្លាប់ដើរមកមុនឯង ឃើញស្តែងអស់ហើយការរាក់ជ្រៅ
ជំនាន់នេះចិត្តច្រើនឃោរឃៅ និត្យនៅជានិច្ចណាចៅអើយ៕

*រៀបរៀងនិងចងក្រងដោយបណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង*

**កំណត់អ្នកស្រាវជ្រាវៈ**

អត្ថបទនេះត្រូវបានលោក បាន តេង (១៨៨២-១៩៥០) ធ្វើជាគ្រូបង្រៀន ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម និងត្រូវបានសមាគម អែមោនិញេរ (Aymonier) ចុះផ្សាយក្នុងសៀវភៅប្រតិទិន "កម្ពុជា" នៅ គ.ស. ១៩៤៦។

ត្រពងមាត់(ន.) = វង្វះមាត់ (គ្រាមភាសា)
កុយជាអើត(កិ.)= កើតជាអុយ (ពាក្យគន្លាស់)
អាណុប(ន.) = កូនប្រុស ឬ ចៅប្រុសសម្លាញ់
ជាងពាក្យ(ន.) = អ្នកនិយាយព្រោកពាក្យសំដីច្រើន
ចៀមខ្លួន(គុ.) = ដែលញឹកញាប់ ដែលសាំដដែលៗ
លិចកញ្ចង់(កិ.) = ហិនហោច វិនាសអន្តរាយទ្រព្យសម្បត្តិ ដោយមារយាទមិនល្អ៕

---

## ស្រីខ្មែរ

**(បទភាគគតិ)**

" ស្រឡាញ់ស្រីខ្មៅ ស្រីខ្មែរមានផៅ មានភព្វត្រកាល
ត្រកូលមានយស ខ្ពង់ខ្ពស់វិសាល ជំទើពៅពាល
ពៅពេញជំទង់។ "

*(ដោយករីសន្ទរវោហា ម៉ុក)*

## ធ្វើមិនដូច

កាលនោះ មានមនុស្សពីរនាក់ជាបងថ្លៃនិងប្អូនថ្លៃនឹងគ្នា។ បងថ្លៃជាកសិករស់នៅទីជនបទ ចំណែកប្អូនថ្លៃវិញជាអ្នកមានទ្រព្យសម្បត្តិ មានកិត្តិយស និងមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅរាជធានី។

ថ្ងៃមួយបងថ្លៃមកលេង ប្អូនថ្លៃក៏បបួលទៅបរិភោគអាហារជួបជុំគ្នានៅគេហដ្ឋានឪពុកក្មេករបស់ខ្លួន។

បងថ្លៃប្រកែក៖

- អរគុណណាស់! បងមិនហ៊ានទៅទេ ព្រោះបងមិនសូវចេះរបៀបរបបហូបចុក ចំណីចំណុកល្អៗទេ ក្រែងចូលជំនុំនឹងគេមិនចុះ នាំខ្មាស់គេ។

ប្អូនថ្លៃក៏ពន្យល់បងថ្លៃថា៖

- បើបងមិនចេះពីរបៀបរបប បងកុំព្រួយ បងចាំមើលតែខ្ញុំ បើខ្ញុំហូបអី បងហូបហ្នឹងទៅ។

បងថ្លៃក៏យល់ព្រមទៅ លុះដល់ពេលបរិភោគ ប្អូនថ្លៃដួសយកលៀសមកជញ្ជក់ ហើយក៏ខ្ទាក់សំបកដាក់នឹងកន្សែងដៃ។ បងថ្លៃធ្វើតាម តែមិនឃើញគេខ្ទាក់សំបកលៀសចោល ក៏នឹកស្មានថាគេស៊ីលៀសទាំងសំបក គាត់ខំទំពាសំបកលៀសទាល់តែល្អិតរួចលេបចូលទៅ។ ប្អូនថ្លៃឃើញដូចនេះលែងស៊ីលៀស បែរទៅស៊ីមីសួរវិញ។ ទើបតែពមចូលក្នុងមាត់ នឹកឃើញបងថ្លៃស៊ីលៀសទាំងសំបក អស់សំណើចទប់មិនឈ្នះ ក៏សើចយឹកៗឡើង មីសួរចេញតាមរន្ធច្រមុះទាំងពីរមកខាងក្រៅ។

បងថ្លៃឃើញដូចនោះ ក៏ស្រវាលើកដៃវា ហើយឧទានថា៖

- ទេ! ទេ! បងលែងស៊ីហើយ លៀសទាំងសំបកបងពិតជាស៊ីបាន តែអារឿងមីសួរខ្លុះច្រមុះ សុំទោសចុះអាប្អូន បងធ្វើមិនដូចទេ!

ប្អូនថ្លៃ៖ !? !? !?

*អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ុំ ថុង*

## អញស្អប់បំផុត!

ថ្ងៃមួយជាពេលប្រឡងឆមាស ពោន និង ទូច អង្គុយតុជាមួយគ្នា។ ទូចអោនក្បាលធ្វើវិញ្ញាសាយ៉ាងញាប់ដៃ។ ចំណែកពោនវិញ យកប៊ិចមកបៀម ភ្នែកសម្លឹងក្តារខៀនស្ទើរធ្លុះ។ ទូចសរសេរបានមួយសន្លឹក ក៏ដាក់ក្បែរពោន ចៃដន្យខ្យល់ប៉ើងក្រដាសព្រាងសង្កត់ទៅលើសន្លឹកវិញ្ញាសា ជាហេតុនាំឲ្យពោនមើលមិនឃើញ។ រំពេចនោះ ពោនយកដៃដាក់ក្បាលទូចមួយក្រញ៉ី គេឮសូរសម្រែកយ៉ាងខ្លាំង ផ្អើលពេញបន្ទប់ប្រឡង៖

ទូច៖ អូយ! ( យកដៃអង្អែលក្បាល ទឹកភ្នែករលីងរលោង ) ម៉េចក៏ឯងខោកក្បាលអញ?

ពោន៖ អញស្អប់បំផុត បើមិនឲ្យមើលទេ កុំយកក្រដាសគ្រប!។

ទូច៖ ?!?!

*និទានកថាប្រជាប្រិយរៀបរៀងដោយ បណ្ឌិតសាស្ត្រាចារ្យ អ៊ុំ ថុង*


ទីស្ដីការគណៈរដ្ឋមន្ត្រី




ទីស្ដីការគណៈរដ្ឋមន្ត្រី



សមាជិក-សមាជិកានៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌